# កម្រងឯកសារ

## គម្រោងអប់រំគ្រូវិទ្យាសាស្ត្រ

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន**

កម្មវិធីបំប៉នលើកទី៣ សម្រាប់នាយកសាលា និងគ្រូឧទ្ទេស
វិទ្យាសាស្ត្រសាលាគរុកោសល្យ និងវិក្រឹតការ រាជធានី-ខេត្ត

១៣ កញ្ញា ដល់ ២៣ កញ្ញា ២០១០







រៀបចំដោយ

**ក្រុមការងារគម្រោង STEPSAM2**

STEPSAM2
Science
Teacher Education Project

# គណៈកម្មការនិពន្ធ

## គណៈកម្មការនិពន្ធ
## សាលាគរុកោសល្យ និងវិក្រឹតការខេត្ត

លោក ណុប វុណ
លោក ប៉ែន ចំរើន
លោក ខែម សារឹម
កញ្ញា ហែម សង្វា

គ្រូឧទ្ទេសវិទ្យាសាស្ត្រ
សាលាគរុកោសល្យ និងវិក្រឹតការខេត្ត

## គណៈកម្មការត្រួតពិនិត្យ

លោក សិត សេង
លោក ម៉ម ចាន់សៀន
លោក ដោ ប៉េងឡុង

## គណៈកម្មការរៀបរៀង និងចងក្រង

លោក ស្រី រតនៈ

# អារម្ភកថា

លោកគ្រូ–អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ជាទីមេត្រី កម្រងឯកសារដែលលោកគ្រូ –អ្នកគ្រូនិងប្រិយ៍មិត្តអ្នកអាន កំពុងកាន់នៅនឹងដៃនេះ គឺជាឯកសារដែលចងក្រងបានពីវគ្គបំប៉នគ្រូឧទ្ទេសវិទ្យាសាស្ត្រនៃសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ទាំង១៨នៅទូទាំងប្រទេស។ វគ្គបំប៉ននេះបានធ្វើនៅវិទ្យាស្ថានជាតិអប់រំ ពីថ្ងៃទី **១៣ កញ្ញា ដល់ថ្ងៃទី ២៣ កញ្ញា ឆ្នាំ ២០១០** ក្រោមកិច្ចសហប្រតិបត្តិការរបស់ក្រសួងអប់រំយុវជន និងកីឡា និងគម្រោងអប់រំគ្រូវិទ្យាសាស្ត្រ (STEPSAM2)ក្នុងគោលបំណងពង្រឹងសមត្ថភាពគ្រូឧទ្ទេសបន្ថែមទៀតលើផ្នែកវិទ្យាសាស្ត្របង្រៀន និងរៀនដោយផ្អែកលើការរិះរក , ការសិក្សាស្រាវជ្រាវមេរៀន និងជំនាញក្នុងការសង្កេតថ្នាក់ ។

ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់លោកគ្រូ –អ្នកគ្រូ និងប្រិយ៍មិត្ត អ្នកអានទាំងអស់ ក្រុមការងារយើងខ្ញុំបានប្រមូលនូវរាល់ឯកសារទាំងអស់ដែលបានប្រើក្នុងវគ្គបំប៉ន សម្រាប់គ្រូ សាលាគរុកោសល្យទាំងអស់មកចងក្រងជាសៀវភៅនេះឡើង។ កម្រងឯកសារនៅក្នុងសៀវភៅនេះ គឺ ជាទន់សម្រាប់ជួយលោកគ្រូ–អ្នកគ្រូអោយអាចកែលម្អការបង្រៀនរបស់ខ្លួនឆ្ពោះទៅរកការបង្រៀន និងរៀនផ្អែកលើការរិះរក ដែលផ្ដោតទៅលើការគិតរបស់សិស្សជាចម្បង។ នៅក្នុងកម្រងឯកសារនេះដែរ មានបង្ហាញពីរបៀបរៀបចំឯកសារមួយចំនួន ដើម្បីឲ្យការបង្រៀនរបស់លោកគ្រូ –អ្នកគ្រូមានសកម្មភាពល្អ ដូចជា កិច្ចតែងការបង្រៀន សន្លឹកកិច្ចការ ប្លង់ក្ដារខៀន និងកំណត់សម្គាល់មេរៀនជាដើម។

ក្រុមការងារយើងខ្ញុំ សូមអធ្យាស្រ័យនូវរាល់ចំណុចខ្វះខាតទាំងឡាយដែលអាចកើតមានដោយយថាហេតុ ទាំងខ្លឹមសារ និងបច្ចេកទេសក្នុងការចងក្រងឯកសារនេះ។

ក្រុមការងារយើងខ្ញុំ រងចាំទទួលការរិះគន់កែលម្អពីសំណាក់លោកគ្រូ–អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ ដើម្បីធ្វើឲ្យកម្រងឯកសារនេះកាន់តែមានសារប្រយោជន៍ដល់ការលើកកម្ពស់ការបង្រៀន និងរៀនថែមទៀត។

**គ្រូឧទ្ទេសថ្នាក់ជាតិ**
**និង**
**ក្រុមការងាគម្រោងអប់រំគ្រូវិទ្យាសាស្ត្រ (STEPSAM2)**

# មាតិកា


គណៈកម្មការនិពន្ធ ........ i
អារម្ភកថា ........ ii
មាតិកា ........ iii

១. កិច្ចតែងការបង្រៀន ផ្អែកលើការរិះរក របស់គ្រូឧទ្ទេសគម្រោង STEPSAM2

១.១. ភ្នែក ........ 1

១.២. ខ្យល់ ........ 6

១.៣. បម្រែបម្រួលគីមី ........ 11

១.៤. ការរំលាយអាហារតាមបែបគីមី ........ 16

២. កិច្ចតែងការបង្រៀនគម្រូ នៅតាមសាលាគរុកោសល្យ និងវិក្រឹតការខេត្ត

២.១. ល្បឿនខ្យល់ ........ 23

២.២. សញ្ញាណអគ្គីសនី "បន្ទុកអគ្គីសនី" ........ 29

២.៣. កំណកញើស ........ 37

២ .៤.ការចង្អុលទិសនៃមេដែក ........ 44

២.៥. ដំណើរប្រែប្រួលនៃរូបធាតុ ........ 52

២.៦. រុក្ខជាតិផ្តល់ជាអាហារ ........ 59

៣. ផែនការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅក្នុងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត

៣.១. ភ្នំពេញ ........ 65

៣.២. កណ្តាល ........ 70

៣.៣. បន្ទាយមានជ័យ ........ 73

៣ .៤. បាត់ដំបង ........ 76

៣.៥. កំពង់ចាម ....................................................................................................79

៣.៦. កំពង់ឆ្នាំង ....................................................................................................82

៣.៧. កំពង់ស្ពឺ ....................................................................................................85

៣.៨. កំពង់ធំ ....................................................................................................88

៣.៩ . កំពត....................................................................................................91

៣.១០. ក្រចេះ ....................................................................................................94

៣.១១. ព្រះសីហនុ ....................................................................................................97

៣.១២. ព្រះវិហារ ....................................................................................................100

៣.១៣. ព្រៃវែង....................................................................................................103

៣.១៤. ពោធិសាត់....................................................................................................106

៣.១៥. សៀមរាប ....................................................................................................109

៣.១៦. ស្ទឹងត្រែង ....................................................................................................112

៣.១៧. ស្វាយរៀង ....................................................................................................115

៣.១៨. តាកែវ ....................................................................................................118

# ១.

# កិច្ចតែងការបង្រៀន ផ្អែកលើការរិះរក

# របស់

# គ្រូឧទ្ទេសគម្រោង

# STEPSAM2

# កិច្ចតែងការបង្រៀន

ថ្នាក់ទី ៤ ជំពូកទី៣៖ មនុស្ស
មេរៀនទី៥៖ **ភ្នែក** ទំព័រ ២២ ដល់២៥
រយៈពេល៖ ៥០ នាទី

I- **វត្ថុបំណង៖**
ក្រោយពីសិក្សាមេរៀននេះចប់ សិស្សអាច
- ពន្យល់ពីរូបផ្តុំភ្នែក និងចលនាភ្នែក
- បកស្រាយពីដំណើរការភ្នែក
- បង្ហាញថារូបភាពកើតឡើងនៅលើអេក្រង់ឈរបញ្ច្រាសពីរូបភាពពិត

II- **សម្ភារបង្រៀន៖**
កែវពង្រីក ក្រដាសកាតុង ក្រដាសកាល់(Tracing paper) កន្ត្រៃ ស្កុត

III- **ដំណើរការបង្រៀន៖**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូបែងចែកសិស្សអង្គុយជាក្រុម<br>-ពិនិត្យអវត្តមានសិស្ស | ជំហ៊ានទី១៖ លំនឹងថ្នាក់ | -សិស្សអង្គុយជាក្រុម<br>-ប្រធានក្រុមរាយការណ៍វត្តមានសិស្ស |
| | ជំហ៊ានទី២៖ រំលឹកមេរៀន | |
| ចូរប្អូនសង្កេតមើលនៅក្នុងថ្នាក់រៀន តើមានអ្វីខ្លះ?<br>តើប្អូនមើលឃើញវត្ថុទាំងនោះបានដោយសារអ្វី?<br><br>-គ្រូឲ្យសិស្សសង្កេតភ្នែកគ្នាទៅវិញ ទៅមក បន្ទាប់មកគូររូបព្រាងភ្នែកដែលគេបានសង្កេតឃើញ<br><br>- តើភ្នែកផ្តុំឡើងដោយសារអ្វីខ្លះ?<br><br>-គ្រូឲ្យសិស្សម្នាក់ៗសង្កេតប្រិច ហើយបំលាស់ទីប្រិចចុះឡើង<br>-តើផ្នែកណាដែលផ្លាស់ទី? | ជំហ៊ានទី៣៖<br>**មេរៀនទី៥៖ ភ្នែក**<br>រូបផ្តុំភ្នែក និងដំណើរការភ្នែក<br><br><br><br> | សិស្សឆ្លើយដូចជា តុ កៅអី គ្រូ ក្តារខៀន។ល។<br><br>-សិស្សសង្កេតភ្នែកគ្នាទៅវិញទៅមក បន្ទាប់មកគូរភ្នែកមិត្តភ័ក្តដែល គេបានសង្កេត<br><br><br>-សិស្សអាចឆ្លើយផ្នែកខ្មៅតូច ផ្នែក ពណ៌ត្នោត និងផ្នែកស។<br>-សិស្សសង្កេតប្រិចដែលមិត្តភ័ក្តធ្វើឲ្យផ្លាស់ទី។<br>-ផ្នែកខ្មៅផ្លាស់ទី។ |

| | | |
|---|---|---|
| -គ្រូបង្ហាញគំរូភ្នែក (ប្រព័ន្ធបិទ) ដល់សិស្ស<br>-គ្រូធ្វើបម្លាស់ទីបិចចុះឡើងនិងឲ្យគំរូភ្នែកផ្លាស់ទីចុះឡើងតាមបម្លាស់ទីបិច<br>-តើភ្នែកខាងក្នុងមានរាងយ៉ាងដូចម្តេច?<br>-គ្រូឲ្យសិស្សស្ទាបភ្នែករៀងៗខ្លួន<br>-គ្រូយកគ្រាប់ភ្នែកគំរូចេញ ហើយបង្ហាញដល់សិស្សថាពិតជារាងស្វែរ<br>-គ្រូបង្ហាញពីភាពដូចគ្នារវាងគំនូសព្រាង និងគំរូភ្នែក<br>-គ្រូឲ្យសិស្សសង្កេតគំរូភ្នែកថាមានកែវភ្នែក និងអេក្រង់នៅខាងក្រោយ<br>-គ្រូបង្ហាញកែវពង្រីក ហើយប្រាប់សិស្សថាវាមានតួនាទីដូចកែវភ្នែក | ភ្នែកមានរាងមូល(ស្វែរ)<br><br>-កែវភ្នែក និងកែវពង្រីកមានតួនាទីដូចគ្នានៅក្នុងករណីនេះ | សិស្សសង្កេតគំរូភ្នែកដែលផ្លាស់ទី<br>-សិស្សប្រហែលថារាងសំប៉ែត ឬមូល<br>-សិស្សឆ្លើយថារាងមូល /ស្វែរ<br>សិស្សសង្កេតគំរូភ្នែក និងមានអ្វីខ្លះនៅលើភ្នែក |
| តើរូបភាពកើតឡើងនៅលើអេក្រង់មានរូបរាងយ៉ាងដូចម្តេចធៀបនឹងវត្ថុ? | | |
| -គ្រូឲ្យសិស្សគិត និងស្មានរូបភាពកើតឡើងនៅលើអេក្រង់<br>-គ្រូឲ្យសិស្សគូររូបភាពកើតឡើងលើអេក្រង់<br>គ្រូឲ្យសិស្សគិតតើត្រូវធ្វើដូចម្តេចដើម្បីបង្ហាញឲ្យឃើញថារូបភាពពិតជាកើតឡើងដូច្នេះមែន<br>គ្រូបង្ហាញសម្ភារ និងពន្យល់ពីរបៀបតម្លើងសម្ភារដោយបញ្ជាក់ថាក្រដាសកាតុង និងគំរូភ្នែករាងស្វែរគឺដូចគ្នាដោយមានឡង់ទី និងអេក្រង់ | <br>សម្ភារៈ កែវពង្រីក ក្រដាសកាតុង ក្រដាសឬប្លាស្ទិចសស្ទើរថ្លា<br>ពិសោធន៍ៈ<br>យកឧបករណ៍ឆ្លុះវត្ថុនានា និង | សិស្សទស្សន៍ទាយចម្លើយ និងឡើងគូររូបភាពលើក្តារខៀន<br><br>សិស្សគិត និងបញ្ចេញយោបល់<br>សិស្សធ្វើការងារជាក្រុមតាមការណែនាំរបស់គ្រូ<br>សិស្សមើលវត្ថុនានាតាមរយៈឧប |

| | | |
|---|---|---|
| គ្រូឲ្យសិស្សមើលវត្ថុនានាតាមរយៈ ឧបករណ៍ដែលគេបានផលិត<br><br>គ្រូឲ្យសិស្សបង្ហាញលទ្ធផល និងគូររូបលើសន្លឹកកិច្ចការ<br><br>គ្រូឲ្យសិស្សសន្និដ្ឋានតាមរយៈលទ្ធផល | សង្កេតរូបភាពកើតឡើងលើអេក្រង់<br><br>លទ្ធផល<br><br>សន្និដ្ឋាន៖<br>រូបភាពលើអេក្រង់ឈរបញ្ច្រាសពីវត្ថុពីលើចុះក្រោម និងពីឆ្វេងទៅស្តាំ<br>-អេក្រង់នៅខាងក្រោយភ្នែក ហៅថារ៉េទីន | ករណី រួចកត់ត្រាលទ្ធផលលើសន្លឹកកិច្ចការ<br><br>សិស្សរាយការណ៍លទ្ធផលតាមក្រុមនិមួយៗ<br><br>សិស្សសន្និដ្ឋាន៖<br>រូបភាពកើតឡើងនៅលើអេក្រង់ឈរបញ្ច្រាសពីវត្ថុ |
| គ្រូបញ្ជាក់បន្ថែមឡើងវិញទៅលើសម្មិតិកម្មដែលសិស្សបានបង្កើត | ជំហានទី៤៖ ពង្រឹងពុទ្ធិ | សិស្សកែសម្មិតិកម្មដែលបានបង្កើតខុស ឬយល់ច្រឡំ |
| សូមមើលមេរៀនបន្ថែមនៅផ្ទះ | ជំហានទី៥៖ បណ្តាំផ្ញើ | សិស្សស្តាប់ និងជំរាបលាគ្រូចេញលេង ឬទៅផ្ទះ |

## សន្លឹកកិច្ចការ

មេរៀនទី៥ ភ្នែក

**ចូរគូសរូបព្រាងភ្នែករបស់មិត្តភ័ក្តិដែលប្អូនបានសង្កេត**

តើរូបភាពកើតឡើងនៅលើអេក្រង់មានរូបរាងយ៉ាងដូចម្តេចធៀបនឹងវត្ថុ?




តើធ្វើដូចម្តេចដើម្បីបង្ហាញថារូបភាពពិតជាកើតឡើងនៅលើអេក្រង់ដូចការគិតរបស់ប្អូន?

លទ្ធផល៖

កែវពង្រីក ឬកែវភ្នែក




ចូរគូសរូបដែលប្អូនបានមើល

រូបភាពមានរាងយ៉ាងដូចម្តេច?
ចូរគូសរូបភាពកើតឡើងលើអេក្រង់!

សន្និដ្ឋាន៖ តើរូបភាពកើតឡើងយ៉ាងដូចម្តេច នៅលើអេក្រង់ តាមរយៈ កែវពង្រីក ឬកែវភ្នែក?

# កិច្ចតែងការបង្រៀន

មុខវិជ្ជា ៖ វិទ្យាសាស្ត្រអនុវត្ត

អំពី ៖ ខ្យល់ (រយៈពេល ១ ម៉ោង)

I– វត្ថុបំណង

- សិស្សអាចពន្យល់បានថាខ្យល់មានទាំងមាឌ និងមានទាំងម៉ាសតាមរយៈការពិសោធន៍បង្ហាញ
- សិស្សមានជំនាញក្នុងការរិះរកពីវិធីធ្វើពិសោធន៍តាមរយៈការងារជាក្រុម
- សិស្សចូលចិត្តធ្វើពិសោធន៍ និងសប្បាយរីករាយក្នុងការរៀនសូត្រ

II– សម្ភារ

ប៉ោងប៉ោង ចង្កឹះឬស្បីវែង ថង់ប្លាស្ទិច កៅស៊ូកង

III– ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យអនាម័យ សណ្តាប់ធ្នាប់ និងវត្តមាន | **ជំហានទី ១**<br>- ពិនិត្យអវត្តមាន<br>- ពិនិត្យអនាម័យ<br>- លំនឹងថ្នាក់ | – ប្រធានថ្នាក់ឡើងរាយការណ៍ |
| យកថង់ប្លាស្ទិចមកបើក និង គ្រវីរួចក្តោបមាត់ថង់ និងសួរថា ៖ តើនៅក្នុងថង់ នេះគឺជាអ្វី ?<br>– តើខ្យល់ជាអ្វី ?<br><br>– តើយើងអាចរស់នៅដោយគ្មានខ្យល់បានទេ ?<br><br>– តើយើងអាចដឹងថាមានខ្យល់ដោយសារអ្វី ? | **ជំហានទី ២ ៖ រំលឹកមេរៀន**<br><br>–ខ្យល់គឺជាល្បាយនៃឧស្ម័នច្រើនប្រភេទ មិនអាច មើលឃើញ គ្មានក្លិន ...<br><br>– មិនបានទេ<br><br>–តាមរយៈការសង្កេតចលនាវត្ថុផ្សេងៗ | – វាជាខ្យល់ ...<br>–ខ្យល់គឺជាល្បាយនៃឧស្ម័នច្រើនប្រភេទ មិនអាចមើលឃើញ គ្មានក្លិន ...<br><br>– មិនបានទេ ។<br><br>– តាមរយៈការសង្កេតធៀបទៅនឹងវត្ថុផ្សេងៗ |
| – តើខ្យល់មានមាឌឬទេ?<br>– តើយើងត្រូវធ្វើដូចម្តេចដើម្បីបញ្ជាក់ថាខ្យល់ពិតជាមានមាឌ ? | – មាន<br>គ្រូធ្វើពិសោធន៍បង្ហាញដោយប្រើធុងទឹក និងកែវ | – មាន/គ្មាន<br>–សិស្សពិភាក្សាគ្នាជាក្រុមដើម្បីរិះរកវិធីបញ្ជាក់ពីភាពមានមាឌ និងគ្មានមាឌរបស់ខ្យល់ ។ |

| | | |
|---|---|---|
| – នៅពេលលោកគ្រូដាក់កែវ ទទេចូលក្នុងធុង តើប្អូន សង្កេតឃើញអ្វី ? នៅពេល លោកគ្រូផ្អៀងកែវ និងលើក កែវចេញពីទឹក តើប្អូនសង្កេត ឃើញដូចម្ដេចដែរ ?<br><br>តាមរយៈការពិសោធន៍នេះ យើង សង្កេតឃើញថាខ្យល់ ក៏មានមាឌ ដែរ ។ ដូចនេះថ្ងៃ នេះយើងនឹង រៀនចំណុចថ្មី នៃមេរៀនរបស់ យើងទៀតគឺ ម៉ាសរបស់ខ្យល់ ។ | នៅក្នុងកែវមិនឃើញអ្វីទេ ពីព្រោះមានខ្យល់នៅក្នុងនោះ។ ពេលផ្អៀងកែវ ខ្យល់ចេញពីក្នុង កែវ រួចទឹកក៏ចូលទៅក្នុងកែវ ។ ពេលលើកកែវហួសពីទឹក ខ្យល់ ក៏ចូលក្នុងកែវ បន្ទាប់ពីទឹកបាន ហូរចេញពីក្នុងកែវបណ្ដើរៗ ។ | –សិស្សរៀបរាប់ពីអ្វីដែលគេ បានសង្កេតឃើញ ។<br>– មានខ្យល់ក្នុងកែវ ពពុះ ខ្យល់ ភាយឡើង<br>– ទឹកចូលក្នុងកែវ ខ្យល់ចូលក្នុង កែវ |
| | **ជំហានទី ៣ ៖ មេរៀនប្រចាំថ្ងៃ**<br>**<u>ម៉ាសខ្យល់</u>** | |
| **សំណួរគន្លឹះ ៖ តើខ្យល់មានម៉ាសឬទេ ?** | | |
| **<u>សម្មតិកម្ម</u>**<br>បិទសំណួរគន្លឹះលើក្ដារខៀន រួចឲ្យសិស្សបង្កើតសម្មតិកម្ម ប្អូនបានបង្កើតសម្មតិកម្មរួច ហើយ ។ ដូច្នេះប្អូនអាចធ្វើ ការពិភាក្សាគ្នាជាក្រុមថាតើ ប្អូនត្រូវធ្វើយ៉ាងណាដើម្បី បញ្ជាក់ថា ខ្យល់មានម៉ាស ឬ គ្មានម៉ាស ។<br>– គ្រូឲ្យសិស្សឡើងបង្ហាញពី ការទស្សន៍ទាយរបស់គេ<br>**<u>ពិសោធន៍</u>**<br>ដូចនេះលោកគ្រូ មានពិសោធន៍ ចំនួនពីរដើម្បី ឲ្យប្អូនៗសង្កេត ទាំងអស់គ្នា | ការបង្កើតសម្មតិកម្មរបស់សិស្ស<br><br>**ពិសោធន៍បង្ហាញចំនួនពីរ ។**<br>ពិសោធន៍ទីមួយចងប៉ោងប៉ោង សង្ខាងនៃដងជញ្ជីងរួចតម្រូវវា ឲ្យស្មើ ។ រួចសប់ប៉ោងប៉ោងម្ខាង និងរក្សា វាទុក និងឲ្យសិស្ស សង្កេតថាតើ វានៅស្មើទៀតឬទេ? ពិសោធន៍ទីពីរ ថ្លឹងប៉ោង ប៉ោងពីរដែលមានខ្យល់ រួចទំ លាយខ្យល់ចេញពីប៉ោងប៉ោង មួយ និងឲ្យសិស្សសង្កេតថាតើវា នៅស្មើទៀតឬទេ ? | សិស្សបង្កើតសម្មតិកម្មតាមក្រុម រួចធ្វើការពិភាក្សាគ្នាដើម្បី រិះរកវិធី ដើម្បីបញ្ជាក់ថាខ្យល់ មានម៉ាស ឬគ្មាន ។<br>– ផ្លុំប៉ោងប៉ោង រួចថ្លឹង<br>– បូមខ្យល់ចូលក្នុងបាល់រួចថ្លឹង ...<br><br>សិស្សសង្កេតមើលពីលទ្ធផល និងសរសេរចូលក្នុងសន្លឹកកិច្ចការរបស់គេ ។ |

| | | |
|---|---|---|
| <u>**លទ្ធផល**</u><br>តាមរយៈការសង្កេតទៅលើពិសោធន៍ទាំងពីរនេះ<br><u>**សន្និដ្ឋាន**</u><br>តើសម្មតិកម្មមួយណាដែលត្រឹមត្រូវ ?<br>–ដូចនេះតើប្អូនអាចសន្និដ្ឋានយ៉ាងដូចម្តេច ? | ខ្យល់ក៏មានម៉ាសដែរ ។ | – សិស្សប្រាប់ពីសម្មតិកម្មដែលត្រឹមត្រូវ ។<br>– ខ្យល់មានម៉ាស |
| តាមរយៈការពិសោធន៍បង្ហាញខាងលើនេះយើង អាចដឹងថាខ្យល់មានទាំងម៉ាស និងមានទាំងមាឌ ។ ដូចនេះតើប្អូនមានសំណួរអ្វី ទាក់ទងទៅនឹងមេរៀនថ្ងៃនេះទេ ? | **ជំហានទី ៤ ៖ ពង្រឹងពុទ្ធិ**<br>ឆ្លើយទៅនឹងសំណួរប្រសិនបើមាន ។ | សិស្សស្តាប់ និងអាចមានសំណួរដូចជា ហេតុអ្វីបានជាប៉ោងប៉ោងមួយចំនួនហោះ ហើយប៉ោងប៉ោងដែលយើងផ្លុំក្នុងថ្នាក់បែរជាមិនហោះ ? |
| នៅពេលត្រឡប់ទៅផ្ទះវិញ ចូរប្អូនគិតមើលថាតើប្អូន អាចមានវិធីអ្វីផ្សេងទៀត ដែលប្អូនអាចប្រើបានដើម្បី បញ្ជាក់ពីមាឌ និងម៉ាសរបស់ខ្យល់ ៕ | **ជំហានទី ៥ ៖**<br>**កិច្ចការផ្ទះ** | សិស្សអាចសាកល្បងវិធីផ្សេងៗដែលគេគិតឃើញ ។ |

# សន្លឹកកិច្ចការ

មេរៀនអំពីខ្យល់

1. តើខ្យល់មានមាឌឬទេ ? មានមាឌ  គ្មានមាឌ 
2. តើយើងធ្វើដូចម្តេចដើម្បីបញ្ជាក់ថា ខ្យល់មាន ឬ គ្មានមាឌ ?
   ចូរពិភាក្សាតាមក្រុមដើម្បីគិតរកវិធីដើម្បីបញ្ជាក់ថាខ្យល់មានមាឌ ឬគ្មានមាឌ ។

   ………………………………………………………………………………………………

   ………………………………………………………………………………………………

3. គ្រូបង្ហាញពីវត្តមានរបស់មាឌខ្យល់ដោយប្រើកែវទឹក និង ធុងកញ្ចក់ដែលមានទឹក ។
   ចូរប្អូនរៀបរាប់ពីអ្វីដែលប្អូនសង្កេតឃើញនៅពេលលោកគ្រូលើកកែវចុះឡើងក្នុងធុងទឹក និងគូររូបបញ្ជាក់ផង

   ក. ពេលផ្កាប់កែវ………………………………………………………………………

   ខ. ពេលផ្អៀងកែវ……………………………………………………………………

   គ. ពេលដកកែវផុតពីទឹក…………………………………………………………………



សំណួរគន្លឹះ ៖ តើខ្យល់មានម៉ាសឬទេ ?

សម្មតិកម្ម ៖ ……………………………………………………………………………………………………
ហេតុអ្វី ? ចូរប្អូនរកវិធីដើម្បីបង្ហាញថា ខ្យល់មានម៉ាស ។

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

**ពិសោធន៍បង្ហាញចំនួនពីរឲ្យសិស្សសង្កេត មើលពីលទ្ធផល និងទាញសន្និដ្ឋាន ។**

**លទ្ធផល៖**

ខ្យល់មានម៉ាស ☐ ខ្យល់គ្មានម៉ាស ☐

ហេតុអ្វីបានជាប្អូនអាចនិយាយបានយ៉ាងដូច្នេះ ?

……………………………………………………………………………………………………

……………………………………………………………………………………………………

**សន្និដ្ឋាន**

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

# កិច្ចតែងការបង្រៀន

១/ សម្រាប់បង្រៀន
២ /មេរៀនៈ បម្រែបម្រួលរូប និងបម្រែបម្រួលគីមី
៣ /រយៈពេលៈ

I- វត្ថុបំណងៈ

-សិស្សអាចបកស្រាយបានពីបម្រែបម្រួលរូប និងបម្រែបម្រួលគីមី។

-សិស្សវិភាគបាពីលក្ខណៈខុសគ្នារវាងបម្រែបម្រួលរូប និងបម្រែបម្រួលគីមី។

-សិស្សមានចំណង់ចំណូលចិត្តក្នុងការធ្វើពិសោធ ដើម្បីបកស្រាយនូវបាតុភូតផ្សេងៗ

II- សម្ភារ

- ទឹក ស្ករស ចង្ក្រានហ្គាស ចាន ស្លាបព្រា។

III- ដំណើរការបង្រៀនៈ

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូត្រួតពិនិត្យថ្នាក់ | **I/ជំហានទី១**<br>អានាម័យ សណ្តាប់ធ្នាប់ អវត្តមាន | ប្រធានថ្នាក់រាយការណ៍ |
| **១- រំលឹកៈ**<br>-ដូម្តេចដែលហៅថាបម្រែបម្រួលរូប?<br>-លំនាំពីៈ<br>អំបិល ⟶ ល្បាយ?<br>ល្បាយ ⟶ សូលុ.?<br>សូលុ. ⟶ អំបិល?<br>តើហៅថាអ្វី? | **II/ជំហានទី ២**<br>**ចំណងជើងមេរៀន**<br>បម្រែបម្រួលរូប និងបម្រែបម្រួលគីមី<br>-ជាបម្រែបម្រួលដែលអ.ធមួយផ្លាស់ប្តូរ រូបរាង ភាពរូប<br>តែលក្ខណៈសំគាល់ផ្ទាល់របស់វានៅដដែល។<br>-ការលាយ, រំលាយ, ច្រោះ, រំហួត។ | -សិស្សឲ្យនិយមន័យទៅលើបម្រែបម្រួលរូប។<br>-សិស្សឆ្លើយៈ<br>ការលាយ, រំលាយ, ច្រោះ, រំហួត, រំពុះ, .....។ |

| | | |
|---|---|---|
| | **III/ជំហានទី៣**<br>**១/ សំណួរគន្លឹះ** | |
| **តើយើងអាចយកស្ករសចេញពីល្បាយដែលមានលាយខ្សាច់ និងស្ករសបានដែរឬទេ?** | | |
| (ចែកសន្លឹកកិច្ចការ)<br>-ឲ្យសិស្សរកវិធីដែលអាចយកស្ករសចេញពីល្បាយខ្សាច់ និងស្ករស ដោយពិភាក្សាតាមក្រុម។<br>-គ្រូទុកពេលឲ្យសិស្សពិភាក្សាគ្នាប្រហែល ១០ នាទី បន្ទាប់មកឲ្យសិស្សតាមក្រុមកត់ត្រាគំនិតដែលអាចញែកស្ករសពីខ្សាច់នៅលើក្រដាស រួចមកបិទនៅលើក្តារខៀន។<br>-ឲ្យតំណាងក្រុមបកស្រាយពីគំនិតរបស់ខ្លួន។<br>-គ្រូឲ្យសិស្សទាំងអស់វិភាគ និងសំយោគវិធីនីមួយៗ។ | **២- សម្មតិកម្ម:**<br>-កើបទាំងខ្សាច់ និងស្ករស រួចរំលាយក្នុងទឹក ច្រោះរួចរំហួតដោយចង្ក្រាន:<br>***ក្នុងករណីនេះគ្រូអាចឲ្យសិស្សធ្វើតាមវិធីដែលគេរកឃើញ។** | -សិស្សពិភាក្សាតាមក្រុមសរសេរនូវគំនិតរបស់ពួកគេ ដែលអាចញែកបាននៅលើសន្លឹកកិច្ចការ។<br>-តំណាងក្រុមឡើងបកស្រាយ។<br>-គំនិតសិស្សអាចធ្វើតាមវិធីញែកអំបិល .....<br>-ក្រុមផ្សេងអាចសួរទៅលើការបកស្រាយរបស់ក្រុមផ្សេងទៀតបាន។ |
| -គ្រូចែកល្បាយខ្សាច់, ស្ករស, និងសម្ភារៈគ្រប់ក្រុម។<br>-ពិនិត្យមើលសកម្មភាពរបស់សិស្ស។ ក្នុងករណី | **៣ -ពិសោធន៍**<br>-សម្ភារ, ខ្សាច់, ស្ករស, ទឹក, ក្រដាសច្រោះ, ជីឡាវ, កែវជ័រ, ចានដែក, ចង្ក្រានហ្គាស និងស្លាបព្រា។ | -សិស្សភ្លក់រសជាតិក្រោយពីទទួលបានស្ករាវ។<br>-សិស្សអនុវត្តពិសោធរហូតដល់ស្ករប្រែជាពណ៌ខ្មៅ ពេលនោះ |

| | | |
|---|---|---|
| ក្រុមសិស្សទទួលបានស្កររាវ គ្រូអោយសិស្សភ្លក់រស់ជាតិ ហិតក្លិន សង្កេត និងមើលពណ៌ស្ករ។ ***សូមកុំភ្លក់សូលុ. ស្ករដែលទើបច្រោះរួច។*** | | សិស្សភ្លក់រសជាតិម្តងទៀត: -កត់ត្រាលើសន្លឹកកិច្ចការ។ |
| -គ្រូឲ្យសិស្សឡើងបង្ហាញពីលទ្ធផលដែលគេទទួលតាមដំណាក់កាលនីមួយៗ | **៤ -លទ្ធផល:**<br>-សូលុ. ជាស្កររាវ ជាស្ករដែលមានលក្ខណ:រាវ រសជាតិផ្អែម<br>-ពណ៌ខ្មៅ ក្លិនឈ្ងៀម<br>រសជាតិល្វីង។ | -សិស្សឡើងបង្ហាញពីលទ្ធផលដែលគេទទួលបាន ក្រោយពីពិសោធន៍ និងសង្កេតក្នុងដំណាក់នីមួយៗ |
| -គ្រូឲ្យសិស្សឡើងវិភាគទៅលើដំណាក់កាលនីមួយៗ ថាវាមានការប្រែប្រួលអ្វីខ្លះនៅពេលធ្វើពិសោធ។<br><br>*គ្រូអាចសំយោគលើលទ្ធផលទទួលរបស់សិស្ស បើសិនរយ:ពេលវាខ្លី។ | **៥- វិភាគ និងសន្និដ្ឋាន:**<br>-ស្ករសលាយជាមួយខ្សាច់ វាជាបម្រែបម្រួលរូប។<br>-រំលាយល្បាយជាមួយទឹកទទួលបានសូលុ. ស្ករស វាជាបម្រែបម្រួលរូប។<br>-ពេលរំហួត ទទួលបានស្ករដែលមានលក្ខណ:ខាប់វាជាបម្រែបម្រួលរូប។<br>-នៅពេលដែលស្ករមានពណ៌ខ្មៅ ក្លិនឈ្ងៀម វាជា<br>បម្រែបម្រួលគីមី។ | -សិស្សក្រុមណាមួយឡើងវិភាគបង្ហាញដល់ក្រុមសិស្សផ្សេងៗទៀត។<br>-សិស្សប្រៀបធៀបលក្ខណ:រូប និងបម្រែបម្រួលគីមី។<br>*សិស្សឲ្យនិយមន័យទៅលើបម្រែបម្រួលគីមី។ |

| | | |
|---|---|---|
| *តើធ្វើយ៉ាងដូចម្តេចដើម្បីទទួលបានស្គរ? គ្រូអោយសិស្សពិសោធម្តងទៀត។ | **IV/ ពង្រឹងពុទ្ធិ**<br>ពិសោធម្តងទៀត។ | *សិស្សពិសោធត្រឹមតែទទួលបានស្គរវារ។ |
| គ្រូអោយសិស្សសាកល្បងក្រឡុកស្វលុ. អ៊ីយ៉ូត រហូតដស់បាត់ពណ៌។ | **V/ កិច្ចការផ្ទះ**<br>បម្រែបម្រួលគីមី | សិស្សអនុវត្ត។ |

# សន្លឹកកិច្ចការ

ថ្ងៃមួយទើបតែងើបពីគេង សារឹម ត្រូវឪពុកប្រើឲ្យទៅទិញស្ករស ព្រោះគាត់អស់ស្ករសផុងកាហ្វេពិសា។

សារឹម ទិញស្ករសបានហើយក៏ប្រញាប់មកផ្ទះយកស្ករសឲ្យឪពុក។ ចៃដន្យ ស្ករសរបូតពីដៃ សារឹម កំពប់ទៅលើដីប្រលាក់អស់រលីង។ សារឹម ភ័យណាស់ព្រោះឪពុកប្រញាប់ទៅធ្វើការផង។ តើសារឹមគិតធ្វើយ៉ាងដូចម្តេច?

| |
|---|
| តើយើងធ្វើយ៉ាងដូចម្តេចដើម្បីទទួលបានស្ករស ពីល្បាយដែលមានខ្សាច់ និងស្ករសមកវិញ? |

**១ / ចូររកវិធីដែលអ្នកអាចយកស្ករពីល្បាយខ្សាច់ និងស្ករសវិញបាន។**

**២/ វិធីក្រោយពីពិភាក្សា**

**៣/ វិភាគ និងសន្និដ្ឋាន**

–ពីស្ករស និងខ្សាច់គេទទួលបាន...........វាជាបម្រែបម្រួល................

–ក្រោយពីរំលាយគេទទួលបាន.............វាជាបម្រែបម្រួល................

–ក្រោយពីរំហួតមួយសន្ទុះវាមានរសជាតិ..........វាជាបម្រែបម្រួល.....

–ស្ករមានពណ៌ខ្មៅ ក្លិនឈ្ងៀម រសជាតិល្វីង វាជាបម្រែបម្រួល..........

ដូចនេះបម្រែបម្រួលគីមីជាបម្រែបម្រួលទាំងឡាយណាដែលអង្គធាតុមួយ .........................ទៅជាអង្គធាតុ..................។

*តើធ្វើយ៉ាងដូចម្តេចដើម្បីទទួលបានស្ករ?

# កិច្ចតែងការបង្រៀន

**ជំពូកទី ៣:** មនុស្ស –

**មេរៀនទី ៦:** ប្រដាប់រំលាយអាហារ (ការរំលាយអាហារ និងជម្រាបអាហារ)

**ប្រធានបទ:** ការរំលាយអាហារតាមបែបគីមី

**រយៈពេលបង្រៀន:** ១ ម៉ោង

I- **វត្ថុបំណង:**

- ចំណេះដឹង: ប្រាប់បានពីការរំលាយអាហារតាមបែបគីមី (ការបំបែកអាមីដុង) និងការផលិតស្ករលុយស្ស៊ុង អាមីដុងបានត្រឹមត្រូវតាមរយៈការណែនាំរបស់គ្រូ
- ជំនាញ: កំណត់អំពីលក្ខណៈខុសគ្នារវាងការបំបែកអាមីដុងដែលចម្អិន និងអាមីដុងមិនចម្អិនជាមួយទឹកមាត់ បានត្រឹមត្រូវតាមរយៈការពិភាក្សា និងពិសោធតាមក្រុម
- ឥរិយាបទ: ទម្លាប់បរិភោគអាហារចំអិនល្អ ដែលងាយស្រួលក្នុងការជួយបំបែកដោយប្រដាប់រំលាយអាហារ

II- **សម្ភារ:**

- ជំឡូងជ្វាឆៅ និងឆ្អិន អង្ករ បាយ នំប៉័ង ផ្លែមៀន ឬសារម៉ាវ ទឹកមាត់ ទឹកអ៊ីយ៉ូត ប្រដាប់ឈូស ចង្ក្រាន កែវជ័រ ឬចាន

III- **ដំណើរការបង្រៀន:**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពគ្រូ | ផ្សេងៗ |
|---|---|---|---|
| គ្រូសួរសិស្ស និងត្រួតពិនិត្យអវត្តមានសិស្ស | ជំហានទី ១ *(២ នាទី)*<br>ត្រួតពិនិត្យវិន័យ អនាម័យ អវត្តមានរបស់សិស្ស និងលំនឹងថ្នាក់ | សិស្សឡើងរាយការណ៍ | |
| - តើរូបផ្តុំប្រដាប់រំលាយអាហារមានអ្វីខ្លះ?<br><br><br><br>- ថ្ងៃនេះ ខ្ញុំមានដំឡូងជ្វាឆៅ និងឆ្អិន អង្ករ បាយ និងនំប៉័ង តើអាហារទាំងអស់នេះសម្បូរ អ្វី?<br>- តើអ្នកធ្វើយ៉ាងដូចម្តេចដើម្បីបង្ហាញថាវាមានអាមីដុងមែនឬអត់? *(ចែកសម្ភារ និងទឹកអ៊ីយ៉ូតដើម្បីធ្វើតេស្ត សាកល្បង)* | ជំហានទី ២: **រំលឹកមេរៀន**<br>*(៥-៨ នាទី)*<br>រូបផ្តុំប្រដាប់រំលាយអាហារ រួមមាន មាត់ ដើមក បំពង់អាហារ ក្រពះ ពោះវៀនតូច ពោះវៀនធំ និងទ្វារធំ<br><br>សេចក្តីផ្តើមភ្ជាប់ទៅនឹងមេរៀនថ្មី<br>វាមានផ្ទុកនូវអាមីដុង<br><br>អាមីដុងធ្វើឱ្យទឹកអ៊ីយ៉ូត ដែលមានពណ៌ត្នោត ប្តូរទៅ ជាពណ៌ខៀវចាស់ រឺក្រម៉ៅ<br><br>វាមានជាតិផ្អែម ហើយគ្មាន ប្រតិកម្មជាមួយទឹកអ៊ីយ៉ូតទេ ដូចនេះវាគ្មានអាមីដុងទេ | - រូបផ្តុំប្រដាប់រំលាយអាហាររួមមាន មាត់ ដើមក បំពង់អាហារ ក្រពះ ថ្លើម លំពែង ពោះវៀនតូច ពោះវៀនធំ និងទ្វារធំ<br><br>- ពួកវាទាំងអស់នេះមានផ្ទុកនូវ អាមីដុង<br><br>- យើងប្រើទឹកអ៊ីយ៉ូត ពីព្រោះប្រតិកម្មរវាង ទឹកអ៊ីយ៉ូត និងអាមីដុង គឺអាមីដុងធ្វើឱ្យទឹកអ៊ីយ៉ូត ដែលមានពណ៌ត្នោត ប្តូរទៅជាពណ៌ខៀវចាស់ រឺក្រម៉ៅ | សរសេរចម្លើយសិស្សលើក្តារខៀន |

| | | | |
|---|---|---|---|
| - ចំណែកឯ ផ្លែមៀន ឬសាម៉ាវ វិញ តើវាមានអាមីដុងដែរឬទេ នៅពេលបន្តក់ទឹកអ៊ីយ៉ូតហើយសង្កេត?<br>- ឥឡូវនេះ ចូរអ្នកទំពារបាយ មួយដុំ នេះមួយរយៈពេល តើវាមានលក្ខណៈយ៉ាងដូចម្ដេចដែរ?<br>ដូចនេះ អាមីដុងត្រូវបានបំបែក ដោយ ទឹកមាត់ | - វាហាក់ដូចជាមានរសជាតិខុសពីរសជាតិដើម | - វាគ្មានប្រតិកម្មជាមួយទឹកអ៊ីយ៉ូតទេ ដូចនេះវាគ្មានអាមីដុងទេ<br><br>- បាយទំពារយូរនៅក្នុងមាត់ វាប្ដូររសជាតិដើមរបស់វា ដោយមានជាតិផ្អែមតិចៗ | |
| | ជំហានទី ៣: មេរៀនថ្មី *(៣៥ នាទី)*<br>**ការរំលាយអាហារតាមបែបគីមី** | | |
| | **តើមានលក្ខណៈខុសគ្នាយ៉ាងដូចម្ដេច រវាងការបំបែកអាមីដុងដែលចំអិន និងអាមីដុងមិនចំអិន ជាមួយទឹកមាត់?** | | |
| - គ្រូដើរចែកសន្លឹកកិច្ចការតាមក្រុម<br><br>- ចូរបង្កើតសម្មតិកម្មហើយសរសេរសម្មតិកម្មនៅលើ ក្ដារខៀន<br><br><br><br><br><br><br>- ដូចនេះ ដើម្បីបញ្ជាក់ពីសម្មតិកម្មរបស់អ្នកត្រឹមត្រូវឬមិនត្រឹមត្រូវ យើងនឹងធ្វើពិសោធទាំងអស់គ្នា<br>- តើយើងត្រូវធ្វើដូចម្ដេចដើម្បី បានអាមីដុងយកមកធ្វើពិសោធ?<br>- ឥឡូវនេះយើងយកដំឡូងជ្វា ទៅឈូសនិង កិនលាយជាមួយ ទឹក បន្ទាប់មកទុកវាឱ្យរង សម្រិតទឹកចេញយើងនឹងឃើញ ម្សៅសៗ នៅបាត នោះជាម្សៅអាមីដុង<br><br>- បង្កើតស្វូលុយស្យុងអាមីដុង ដែល មិនចំអិន និងអាមីដុង ដែលអិនដោយកម្ដៅ ហើយវាទាំង២ | ចែកសន្លឹកកិច្ចការតាមក្រុមនីមួយៗ<br><br>**បង្កើតសម្មតិកម្ម**<br>អាមីដុងដែលចំអិនងាយបំបែកទៅជាគ្លុយកូសជាង អាមីដុង ដែលមិនចំអិន ដោយអង់ស៊ីម អាមីឡាស<br><br><br><br><br><br>យកចេញពីដំឡូងជ្វា អង្ករ ដំឡូងបារាំង ឬពោត .....<br><br>**ការធ្វើពិសោធ និងសង្កេតលទ្ធផល**<br><u>(២៥ នាទី)</u><br>បង្ហាញសកម្មភាពក្នុងការយក អាមីដុងពីដំឡូងជ្វា<br><br><br>វាលក្ខណៈខុសគ្នា គឺអាមីដុងចំអិនថ្លា ហើយអាមីដុងមិនចំអិនល្អក់ | - ទទួលបានសន្លឹកិច្ចការតាមក្រុម<br><br>- វាមានលក្ខណៈដូចគ្នា<br>- វាមានលក្ខណៈខុសគ្នា គឺ អាមីដុងដែលចំអិនងាយបំបែកជាងអាមីដុងមិនចំអិន ខ្លះថា អាមីដុងដែលមិន ចំអិន ងាយបំបែកជាង អាមីដុងចំអិន<br><br>- យើងយកពីដំឡូងជ្វា អង្ករ ឬពោត ......<br><br>- សង្កេតមើលការបង្ហាញ ក្នុងការយកអាមីដុងពីដំឡូងជ្វា ហើយបង្កើតជាស្វូលុយស្យុង អាមីដុងដែលចំអិន និង អាមីដុង ដែលមិនចំអិន ព្រមទាំងការ បង្កើត សូលុយស្យុង ទឹកមាត់។<br>- ស្វូលុយស្យុងអាមីដុង ដែលចំអិនមានលក្ខណៈថ្លាជាង ស្វូលុយស្យុង អាមីដុងមិនចំអិន។ | - បម្រុងប្រយ័ត្នការលាយស្វូលុយស្យុងអាមី ដុង *(កុំឱ្យមានកំហាប់ខ្ពស់)* |

| | | | |
|---|---|---|---|
| ខុសគ្នាដូចម្ដេចដែរ?<br>- បង្កើតសូលុយស្យុងទឹកមាត់ ដោយបៀបដុំទឹកកកតូចៗ ឬទឹកឆ្អិនបន្តិច<br>- ចែកសម្ភារៈទៅតាមក្រុមនីមួយៗ ហើយឱ្យគេអនុវត្តតាមដំណាក់កាលពិសោធ។ គ្រូធ្វើមើលនិងសម្របសម្រួលតាមក្រុមនីមួយៗ | គ្រូដើរមើល និងសម្របសម្រួលតាមក្រុមនីមួយៗ | - រៀបចំអនុវត្តតាមដំណាក់កាលពិសោធ និងសង្កេតមើល ហើយកត់ត្រា លទ្ធផលចូលក្នុងសន្លឹក កិច្ចការតាមក្រុមនីមួយៗ | *បរិមាណទឹកមាត់សំរាប់បំបែកអាមីដុងអាស្រ័យនឹងបុគ្គលម្នាក់ៗ |
| - បន្ទាប់ពីអ្នក បន្តក់ទឹកអ៊ីយ៉ូត ចូលសូលុយស្យុងអាមីដុងនៃ កែវនីមួយៗ តើអ្នកសង្កេតឃើញ មានពណ៌អ្វី?<br><br>- ក្រោយពីចាក់សូលុយស្យុងទឹកមាត់ តើអ្នកសង្កេតឃើញមានអ្វីនៅក្នុងចាន ឬកែវជ័រនីមួយៗ។ ចំណែកពណ៌របស់អ៊ីយ៉ូតមានពណ៌អ្វីដែរក្រោយពីបន្តក់?<br><br>- មូលហេតុអ្វីបានជាពណ៌របស់ អ៊ីយ៉ូតមិនប្រែពណ៌ ហើយនៅ ពណ៌ត្នោតដដែរ?<br><br>- សូលុយស្យុងអាមីដុងដែល ចំអិន និងអាមីដុងដែលមិនចំអិន មានលក្ខណៈខុសគ្នា ដូចម្ដេចដែរ នៅក្រោមអំពើ របស់ទឹកមាត់ *(អង់ស៊ីមអាមីឡាស)*? | **វិភាគ និងទាញសេចក្ដីសន្និដ្ឋាន**<br>*(១៥ នាទី)*<br>មានពណ៌ខៀវ<br><br>ភាគល្អិតតូចៗត្រូវបានរលាយ ពីក្នុងកែវ ឬពណ៌ខៀវត្រូវបានប្ដូរ ទៅជាអត់ពណ៌<br><br>ពណ៌របស់អ៊ីយ៉ូតនៅមានពណ៌ ត្នោតដដែរ ព្រោះវាគ្មានម៉ូលេគុលអាមីដុងដែល ម៉ូលេគុលអាមីដុងនេះ ត្រូវបំបែកទៅជាម៉ូលេគុល ស្ករអស់<br><br>វាមានលក្ខណៈខុសគ្នាគឺ សូលុយស្យុង អាមីដុងដែលចំអិនហាក់ដូចជាងាយ រលាយ ឬបំបែកដោយទឹកមាត់ជាង សូលុយស្យុងអាមីដុងដែល មិនចំអិន | - វាប្រែពីពណ៌ត្នោតទៅជាពណ៌ខៀវខ្ចី ឬខៀវចាស់ ទាំងពីរកែវ<br><br>- សង្កេតឃើញគ្រាប់ល្អិតតូចៗ ត្រូវបានរលាយ ឬ ពណ៌ខៀវ ត្រូវបានប្ដូរទៅ ជាអត់ពណ៌ និង ពណ៌របស់ អ៊ីយ៉ូតនៅមានពណ៌ត្នោត<br>- នៅពណ៌ត្នោតដដែរ ព្រោះ វាគ្មានម៉ូលេគុលអាមីដុង ដោយវា ត្រូវបំបែកទៅជា ម៉ូលេគុលស្ករ<br><br>- វាមានលក្ខណៈខុសគ្នាគឺ សូលុយស្យុងអាមីដុងដែល ចំអិនហាក់ដូចជាងាយ រលាយ ឬបំបែកដោយ សូលុយស្យុងទឹកមាត់ ជាង សូលុយស្យុង អាមីដុងដែល មិនចំអិន ដោយសារម៉ូលេគុលអាមីដុង ត្រូវបានរលាយ ឬបំបែកលឿន ដោយទឹកមាត់ *(ដែលមាន អង់ស៊ីម* | |

| | | | |
|---|---|---|---|
| - តើដំណើរការនៃការបំបែកអាហារត្រូវបានគេហៅដូចម្តេច?<br>- តើយើងគួរញ៉ាំអាហារបែបណាដើម្បីអោយមានសុខភាពល្អ? | - ដំណើរការបែបនេះហៅថា ការរំលាយអាហារបែបគីមី<br><br>- បរិភោគអាហារដែលចម្អិនល្អ ដើម្បីងាយស្រួលបំបែកដោយ ប្រដាប់រំលាយអាហារ | *អាមីឡាស)*<br>- ជាការរំលាយអាហារបែបគីមី<br>- យើងត្រូវបរិភោគអាហារដែលចម្អិនល្អដើម្បីងាយស្រួលបំបែកដោយប្រដាប់រំលាយអាហារ | |
| - តើទឹកមាត់មានតួនាទីដូចម្តេចដែរ?<br>- ដូចម្តេចដែលហៅថាការរំលាយអាហារបែបគីមី? | **ជំហានទី 4**<br>**ពង្រឹងពុទ្ធិ**<br>*(៣-៥ នាទី)* | - វាមានតួនាទីជួយបំបែកអាមីដុងទៅជាម៉ូលេគុលស្ករ<br>- វាជាការបំបែកដោយប្តូរទ្រង់ទ្រាយ ពីមួយទៅមួយទៀត ដែលយើងមិនអាចមើលឃើញ | |
| - ថ្ងៃនេះយើងយកអាមីដុងពី ដំឡូងចំនែកអាមីដុងដែលចំអិន និងអាមីដុងដែលមិនចំអិន របស់ពោត វាមានលក្ខណៈ ដូចម្តេចដែរ?<br>- ប្រៀបធៀបការរំលាយអាហារបែបមេកានិច និងបែបគីមី | **ជំហានទី 5**<br>**បណ្តាំផ្ញើ និងកិច្ចការផ្ទះ**<br>*(២-៣ នាទី)* | - កត់ត្រាសំណួរទាំងអស់ ចូលក្នុងសៀវភៅ | |

## សន្លឹកកិច្ចការ

### ការរំលាយអាហារតាមបែបគីមី

អាមីដុងមានសម្បូរនៅក្នុងអាហារដូចជា ដំឡូងជ្វា ដំឡូងបារាំង អង្ករ និងពោត ជាដើម។ អាមីដុងជាម៉ាក្រូម៉ូលេគុល ដែលបង្កឡើងដោយបណ្តុំនៃគ្លុយកូសដ៏ច្រើន បង្កើតបានជាច្រវ៉ាក់យ៉ាងវែង។ ចំណងគ្លុយកូសនៅក្នុង អាមីដុងត្រូវបានផ្តាច់ដោយអង់ស៊ីម អាមីឡាសដែលមាននៅក្នុងទឹកមាត់ និង រសលំពែង។ វត្តមានរបស់អាមីដុងធ្វើឱ្យ ពណ៌របស់ទឹកអ៊ីយ៉ូត ដែលមានពណ៌ដើមជាពណ៌ត្នោត នឹងប្រែទៅជាពណ៌ខៀវចាស់ ឬខៀវក្រម៉ៅ។

| |
|---|
| **តើមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច រវាងការបំបែក អាមីដុងដែលចំអិន និងអាមីដុងមិនចំអិន ជាមួយទឹកមាត់?** |

ការបង្កើតសម្មតិកម្ម

……………………………………………………………………

……………………………………………………………………

សម្ភារៈ

……………………………………………………………………

……………………………………………………………………

**ដំណើរការ**

- ការបង្កើតសូលុយស្យុងអាមីដុងមិនចំអិន និងអាមីដុងដែលចំអិនដោយកម្តៅ
- ការបង្កើតសូលុយស្យុងទឹកមាត់ ដោយបៀមដុំទឹកកក ឬទឹកឆ្អិនបន្តិច

**ពិសោធ និងសង្កេតលទ្ធផល**

១. យកស៊ីរ៉ាំងបូមទឹកសូលុយស្យុងអាមីដុងដែលចំអិន ចូលក្នុងចាន ឬកែវជ័រ (A) និងអាមីដុងដែល មិនចំអិន ក្នុងចាន ឬកែវជ័រ (B) ក្នុងបរិមាណស្មើៗគ្នា ប្រហែល ១-២ មីលីលីត្រ (រូបទី 1)

២. បន្តក់ទឹកអ៊ីយ៉ូត ១-២ ដំណក់ចូលក្នុងចាននីមួយៗពេលដំណាលគ្នា រួចសង្កេត(រូបទី 2)។



រូបទី 1



រូបទី 2

លក្ខណៈសូលុយស្យុងនៅក្នុង

ចាន ឬកែវជ័រ A

.............................................................

ចាន ឬកែវជ័រ B

.............................................................

៣. បន្ថែមសូលុយស្យុងទឹកមាត់ ក្នុងបរិមាណស្មើគ្នា (១០-១៥ ម.ល) ទៅក្នុងចាននីមួយៗ ហើយ គ្រឡុកចាននីមួយៗថ្នមៗ រយៈពេល ៣-៥ នាទីស្មើគ្នា ព្រមទាំងធ្វើការសង្កេតនៅក្នុង

ចាន ឬកែវជ័រ A .................................................

ចាន ឬកែវជ័រ B ................................................

៤. ដើម្បីបញ្ជាក់ពីវត្តមានរបស់អាមីដុងឡើងវិញ នៅក្នុងចាន ឬកែវជ័រ នីមួយៗ ចូរបន្តក់ ទឹកអ៊ីយ៉ូត ១-៣ ដំណក់ទៅ ក្នុងចាន ឬកែវជ័រនីមួយៗ ហើយសង្កេតមើលសូលុយស្យុងក្នុង

ចាន ឬកែវជ័រ A .................................................

ចាន ឬកែវជ័រ B.................................................

វិភាគ និងសន្និដ្ឋាន

១. ហេតុអ្វីបានជាក្រោយពេលបន្តក់ទឹកអ៊ីយ៉ូត ពណ៌អ៊ីយ៉ូតនៅក្នុង ចាន ឬកែវជ័រ A មានពណ៌ខ្មៅ ?

............................................................

............................................................

២. ហេតុអ្វីបានជាក្រោយពេលបន្តក់ទឹកអ៊ីយ៉ូត ពណ៌អ៊ីយ៉ូតនៅក្នុង ចាន ឬកែវជ័រ B មិនមានពណ៌ខ្មៅ ?

............................................................

............................................................

យើងអាចទាញសេចក្ដីសន្និដ្ឋានថា

............................................................

............................................................

# ២.

# កិច្ចតែងការបង្រៀនគម្រូ

# នៅតាម

# សាលាគរុកោសល្យ និងវិក្រឹតការខេត្ត

# កិច្ចតែងការបង្រៀន

មុខវិជ្ជា វិទ្យាសាស្ត្រអនុវត្ត
ថ្នាក់ទី៤
មេរៀន ល្បឿនខ្យល់ (រយៈពេល ៤៥នាទី)

I– វត្ថុបំណង:

- ចំណេះដឹង: សិស្សប្រាប់បានពីបាតុភូតផ្សេងៗ ដែលបណ្តាលមកពីកម្លាំងខ្យល់បក់ បានត្រឹមត្រូវតាមរយៈសំណួរបំផុសលើសម្ភារៈជាក់ស្តែង។
- បំណិន: សិស្សពន្យល់ និងបកស្រាយពីល្បឿននៃខ្យល់បានច្បាស់លាស់តាមរយៈការពិសោធការងារក្រុម។
- ឥរិយាបថ: ទម្លាប់សិស្សអោយដឹងពីវិធីការពារខ្លះៗ ពីគ្រោះថ្នាក់ផ្សេងៗដែលបណ្តាលមកពីល្បឿននៃប្រភេទខ្យល់មួយចំនួន។

II– សម្ភារ:

- ចំពោះគ្រូ: ប៉ោងៗ កំទេចក្រដាស ក្រដាស A4
- ចំពោះសិស្ស: សៀវភៅកត់ត្រា សន្លឹកកិច្ចការ

III– ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . ត្រួតពិនិត្យលំនឹងថ្នាក់ | ជំហានទី១ (៣នាទី)<br>ពិនិត្យ អនាម័យ សណ្តាប់ធ្នាប់ វត្តមាន | ប្រធានថ្នាក់ឡើងរាយការណ៍ |
| . ឲ្យសិស្សយកកិច្ចការជូនគ្រូកែ<br><br>. កាលថ្ងៃមុនវិទ្យាសាស្ត្ររៀនពីមេរៀនអ្វី?<br>. តើប្រភេទខ្យល់មានខ្យល់អ្វីខ្លះ?<br><br>. តើប្អូនធ្លាប់ឃើញស្លឹកឈើបក់ដែរឬទេ? បក់ដោយសារអ្វី?<br>. តើស្លឹកឈើបក់តិចៗ និងបក់ខ្លាំងៗបណ្តាលមកពីអ្វី? | ជំហានទី២ (៧នាទី)<br>ត្រួតពិនិត្យកិច្ចការចាស់<br>**រំលឹកមេរៀនចាស់**<br>**<u>ចលនាខ្យល់</u>**<br>. ខ្យល់ព្យុះ ខ្យល់គួច ខ្យល់បក់ ខ្យល់កំបុតត្បូង ខ្យល់ជំនោរ...<br>**<u>ទំនាក់ទំនងមេរៀន</u>**<br>. ធ្លាប់ឃើញស្លឹកឈើបក់ វាបក់ដោយសារខ្យល់។<br>. ស្លឹកឈើបកតិចៗគឺមានខ្យល់តិច<br>. ស្លឹកឈើបក់ខ្លាំងគឺមានខ្យល់ខ្លាំង | . យកកិច្ចការអោយគ្រូកែ<br><br>. ឆ្លើយជាបុគ្គល<br><br>. ឆ្លើយជាបុគ្គលតាមការយល់ដឹង<br><br>. ឆ្លើយតាមការជាក់ស្តែង<br><br>. ឆ្លើយតាមការយល់ដឹងជាបុគ្គល |

| | | |
|---|---|---|
| . តើខ្យល់បក់តិច និងខ្យល់បក់ខ្លាំង គេហៅថាអ្វី?<br>. តើថ្ងៃនេះយើងរៀនមេរៀនអ្វី | | . ហៅថាល្បឿនខ្យល់<br><br>. ល្បឿនខ្យល់ |
| . តើខ្យល់បក់ខ្លាំងអាចបណ្តាលអោយមានបាតុភូតអ្វីខ្លះ?<br><br>. ចែកសិស្សជា៤ក្រុម<br>. បិទក្រដាសសំណួរគន្លឹះ | ជំហានទី៣ (៣០នាទី)<br>**ល្បឿនខ្យល់**<br>. កំរើកស្លឹកឈើខ្លាំងវក់វី ហុយដី ក្ងួចសំរាម បាក់មែកឈើ រលំដើមឈើ រលំផ្ទះ...។ | . ឆ្លើយម្នាក់មួយចំណុចតាមការធ្លាប់ជួបប្រទេះ។ |

តើមានអ្វីខុសគ្នាពេលយើងអោយខ្យល់ចេញពីប៉ោងៗធំ និងប៉ោងតូច?

| | | |
|---|---|---|
| . យកសន្លឹកកិច្ចការចែកអោយសិស្សពិភាក្សាក្រុមនូវបញ្ហាលើក្រដាសកិច្ចការ (២នាទី) | | . សិស្សពិភាក្សាលើសន្លឹកកិច្ចការ |
| . អោយសិស្សតាមក្រុមសរសេរសម្មតិកម្មលើក្រដាស A4 រួចឡើងបង្ហាញ (៣នាទី) | . សម្មតិកម្មដែលសិស្សសរសេរ<br>. ល្បឿនខ្យល់អាចធ្វើចលនា តិច ខ្លាំង ...។ | . សរសេរសម្មតិកម្មតាមក្រុមហើយឡើងបកស្រាយ។ |
| . ដើម្បីធ្វើពិសោធន៍ តើប្អូនៗត្រូវការសម្ភារៈអ្វីខ្លះ? | . សម្ភារៈលើតុគ្រូមាន៖ ប៉ោង កំទេចក្រដាស។ | . គិតហើយជ្រើសសម្ភារៈពិសោធន៍ |
| . កំណត់រយៈពេលពិសោធន៍ (៧នាទី) | | . ពិសោធន៍តាមក្រុម |
| . អោយសិស្សតាមក្រុមឡើងបកស្រាយពីរបៀបដែលបានធ្វើពិសោធន៍ និងបំពេញសន្លឹកកិច្ចការលើលទ្ធផលដែលបានពិសោធន៍ | • **ពិសោធន៍ទី១**<br>. យកប៉ោងៗមួយមកផ្លុំបញ្ចូលខ្យល់អោយពេញ<br>. ដាក់កំទេចក្រដាសលើតុ<br>. កាន់មាត់ប៉ោងៗដាក់ក្បែរកំទេចក្រដាសប្រហែល ២០ស.ម។<br><br> | . តំណាងក្រុមឡើងបកស្រាយពីរបៀបធ្វើពិសោធន៍ និងបង្ហាញពីលទ្ធផលពិសោធន៍។ |

| | | |
|---|---|---|
| . តើការពិសោធន៍ទាំងពីរនេះប្អូនសង្កេតឃើញបាតុភូតកើតឡើងដូចម្តេច? ព្រោះអ្វី?<br>. គ្រូចូលរួមសំយោគសំណួរចម្លើយ និងផ្ទៀងផ្ទាត់សម្មតិកម្មខាងលើ<br>. អោយសិស្សវិភាគធ្វើសន្និដ្ឋានលើការពិសោធន៍ល្បឿនខ្យល់។<br>. ហេតុអ្វីបានជាក្រសួងឧតុនិយមតែងតែប្រកាសតាមវិទ្យុ ទូរទស្សន៍ ស្តីពីសីតុណ្ហភាព ប្រចាំថ្ងៃ ល្បឿនខ្យល់....ដើម្បីអ្វី?<br>. អោយសិស្សអានការសន្និដ្ឋាន | • ពិសោធន៍២<br>. យកប៉ោងៗមួយមកផ្លុំបញ្ចូលខ្យល់ប៉ោងធំ។<br>. ដាក់តាមប៉ោងៗក្បែរកំទេចក្រដាសចំងាយ២០ ស.ម ដូចមុន ហើយបង្ហើបមាត់ប៉ោងៗអោយខ្យល់ចេញយ៉ាងខ្លាំង។<br><br>សន្និដ្ឋានៈ<br>. ខ្យល់អាចធ្វើចលនាជួនយឺត ជួនកាលខ្លាំង ជួនកាលតិច ខ្យល់បក់ខ្លាំងគឺខ្យល់ព្យុះ។<br>. ដើម្បីអោយប្រជាជនមានបំរុងប្រយ័ត្នក្នុងការធ្វើដំណើរ ការពារផ្សេងៗ...។<br>(ខ្លឹមសារខាងលើ) | . បំពេញ និងផ្ទៀងផ្ទាត់ចម្លើយដែលបានធ្វើពិសោធន៍ខាងលើ<br>. ធ្វើការសន្និដ្ឋាន និងផ្ទៀងផ្ទាត់លើសន្លឹកកិច្ចការ<br>. ឆ្លើយតាមរយៈធ្លាប់ជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ<br>. អានការសន្និដ្ឋាន |
| . ល្បែងប្រណាំងកង្ហែប<br>. ដើម្បីអោយកង្ហែបទៅលឿនតើយើងត្រូវធ្វើដូចម្តេច?<br>. ទឹករលកទន្លេប្រដេញគ្នាតិចៗបណ្តាលអោយមកពីអ្វី?<br>. ចុះទឹករលកខ្លាំងៗដូចម្តេចដែរ?<br>. ខ្យល់បក់ទៅប៉ះទូក កប៉ាល់ នាវា លិចផ្ទះបាក់រលំ ដើមឈើដួលបណ្តាលមកពីអ្វី? | ជំហានទី៤ (៧នាទី)<br>. ប្រណាំង<br>. បក់អោយខ្លាំង<br>. បណ្តាលមកពីទឹករលកប៉ះល្បឿនខ្យល់តិចៗ<br>. រលកខ្លាំងបណ្តាលមកពីទឹករលកប៉ះល្បឿនខ្យល់ខ្លាំង<br>. បណ្តាលមកពីល្បឿនខ្យល់ខ្លាំងហៅថាខ្យល់ព្យុះ | . សិស្សអនុវត្ត<br>. ឆ្លើយតាមការយល់ដឹង<br>. ឆ្លើយតាមការយល់ដឹង<br>. ឆ្លើយតាមការយល់ដឹង<br>. ឆ្លើយតាមការយល់ដឹង |
| . អោយសិស្សកត់មេរៀន កិច្ចការធ្វើនៅផ្ទះ និងបណ្តាំផ្ញើ | ជំហានទី៥ (៣នាទី) កិច្ចការផ្ទះ<br>. ពេលមានអគ្គីភ័យហេតុអ្វីមានខ្យល់ខ្លាំង? | កត់មេរៀន និងកិច្ចការផ្ទះចូលក្នុងសៀវភៅ។ |

## សន្លឹកកិច្ចការ

**សំណួរ: តើល្បឿនខ្យល់តិច និងល្បឿនខ្យល់ខ្លាំងមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច?**

១. ចូរប្អូនសរសេរសម្មតិកម្ម

------------------------------------------------------------

------------------------------------------------------------

២. ដើម្បីធ្វើពិសោធន៍ ពីល្បឿនខ្យល់អាចធ្វើចលនា តើប្អូនត្រូវការសម្ភារៈអ្វីខ្លះ?

------------------------------------------------------------

------------------------------------------------------------

៣. ចូរប្អូនរៀបរាប់ពីរបៀបធ្វើពិសោធន៍

- ពិសោធន៍ទី១(ល្បឿនខ្យល់តិច)

------------------------------------------------------------

------------------------------------------------------------

- ពិសោធនទី២(ល្បឿនខ្យល់ខ្លាំង)

------------------------------------------------------------

------------------------------------------------------------

៤. ក្រោយពីធ្វើពិសោធន៍ទាំងពីរលើក តើប្អូនៗសង្កេតឃើញល្បឿនខ្យល់យ៉ាងដូចម្តេចខ្លះ?

- លទ្ធផលពិសោធន៍ទី១

------------------------------------------------------------

------------------------------------------------------------

- លទ្ធផលពិសោធន៍ទី២

------------------------------------------------------------

------------------------------------------------------------

៥. សន្និដ្ឋាន

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

## យោបល់ និងសំណូមពរ

ចំណុចល្អ
- សិស្សបានចូលរួមសកម្មភាពរៀនយ៉ាងសកម្ម
- សម្ភារៈសំរាប់ពិសោធន៍គ្រប់គ្រាន់
- មានសំណួរបំផុសទាក់ទងនិងមេរៀន
- មានទំនាក់ទំនងល្អជាមួយសិស្ស
- សិស្សមានសកម្មភាពច្រើន
- ឲ្យសិស្សបង្កើតសម្មតិកម្ម
- ឲ្យសិស្សិសរសេរប្លង់ពិសោធន៍
- ដើរពិនិត្យសកម្មភាពតាមក្រុម
- សំយោគលទ្ធផល
- មានទំនាក់ទំនងមេរៀនៈ ខ្យល់បក់ខ្លាំងតិច អាស្រ័យលើអ្វី?
- បង្ហាញលទ្ធផលពិសោធន៍
- ទាញសេចក្តីសន្និដ្ឋាន
- ផ្សារភ្ជាប់ខ្លឹមសារទៅនឹងការអនុវត្តន៍ក្នុងជីវភាពជាក់ស្តែង
- មានល្បែងប្រណាំងកង្កែប
- មានលំហាត់ធ្វើនៅផ្ទះ
- លើកទឹកចិត្តសិស្សក្នុងការឆ្លើយសំណួរ
- របៀប វិធីពិសោធន៍ខុសៗគ្នា សិស្សការយកចិត្តទុកដាក់
- សួរសិស្សពីហេតុផលផ្សេងៗ
- ប្រើប្រាស់តាមវិធីវិទ្យាសាស្រ្ត
- សិស្សបង្កើតសម្មតិកម្មដោយខ្លួនឯង
- សិស្សបំពេញសន្លឹកកិច្ចការនិងទាញសន្និដ្ឋានខ្លួនឯងដោយបង្ហាញលើ Flipchart.
- បានសម្រេចវត្ថុបំណង

ចំណុចកែលម្អ

- សកម្មភាពគ្រូយឺតណាស់ពេលបង្រៀន
- ការសន្និដ្ឋានរបស់សិស្សមិនឆ្លើយតបនឹងសំណួរគន្លឹះ
- គ្រូនិយាយច្រើនជាងសិស្ស
- សួរសំណួរទៅលើសិស្សដដែលៗ
- នៅពេលធ្វើពិសោធន៍គ្រូមិនបានណែនាំសិស្សឲ្យបានច្បាស់លាស់ទេ ។
- សូមកំណត់វត្ថុបំណងឲ្យបានច្បាស់ជាមួយនិងសំណួរគន្លឹះ
- ភ្លេចកំណត់រយៈពេលធ្វើពិសោធន៍
- សរសេរសំណួរគន្លឹះខុសៈ

    តើខ្យល់បក់តិចនិងខ្យល់បក់ខ្លាំង ហៅថាអ្វី ?

- សូមកែសំណួរគន្លឹះដែលមិនត្រូវទៅតាមកិច្ចតែងការឲ្យត្រូវតាមកិច្ចតែងការ
- សិស្សទាញសម្មតិកម្មចាកឆ្ងាយពីខ្លឹមសារ
- កំណត់ឲ្យសិស្សពិសោធន៍តាមគ្រូ (ក្រុមចង់ពិសោធន៍តាមសម្ភារៈរបស់គេ)
- មុនពេលពិសោធន៍គ្រូគួរណែនាំឲ្យច្បាស់
- គ្រូនិយាយច្រើន ឯសិស្សមិនសូវបានធ្វើសកម្មភាព (ជួយឲ្យសិស្សអនុវត្តឲ្យបានច្រើនជាងគ្រូ)។
- ល្បែងកង្កែប ឬអនុវត្តនៅតាមក្រុមសិស្ស
- ត្រូវណែនាំឲ្យសិស្សធ្វើពិសោធន៍តាមលំដាប់
- គ្រូបែងចែកប្រធានក្រុម លេខា លេខារង អ្នករាយការណ៍
- ការលើកទឹកចិត្តនៅមានកម្រិត
- ពេលពិសោធន៍គ្រូមិនបានដើរត្រួតពិនិត្យឲ្យបានគ្រប់ក្រុម
- ការសន្និដ្ឋានរបស់សិស្សមិនឆ្លើយតបទៅនឹងសំណួរគន្លឹះ
- គួរផ្តល់ឱកាសឲ្យសិស្សធ្វើពិសោធន៍តាមការបង្កើតប្លង់ពិសោធន៍របស់ពួកគេ
- ការប្រើប្រាស់ក្ដារខៀនមានលំដាប់លំដោយ
- គួរតែឲ្យសិស្សឡើងអានសេចក្ដីសន្និដ្ឋានតាមក្រុមនីមួយៗ
- គួររៀបចំសំណួរគន្លឹះឲ្យបានសមស្របទៅនឹងវត្ថុបំណងនិងសេចក្ដីសន្និដ្ឋាន
- ឲ្យពិនិត្យការងារក្រុម ឲ្យបានពិភាក្សាគ្នាជាក្រុម ជៀសវាងជាបុគ្គល ។
- មិនឲ្យសិស្សធ្វើពិសោធន៍គួរបញ្ជាក់ពីសម្មតិកម្មរបស់សិស្សសិន
- គួរមានការលើកទឹកចិត្តសិស្ស

# កិច្ចតែងការបង្រៀន

មុខវិជ្ជា   វិទ្យាសាស្ត្រអនុវត្ត

មេរៀនទី១៧  សញ្ញាណអគ្គីសនី "បន្ទុកអគ្គីសនី"

ដកស្រង់ពីសៀវភៅ វិទ្យាសាស្ត្រអនុវត្ត សម្រាប់បំប៉នគ្រូឧទ្ទេសសាលាគរុកោសល្យខេត្តក្រុង ទំព័រ ៩៨ និង៩៩។

រយៈពេល ១ម៉ោង

I–  វត្ថុបំណង

- សិស្សប្រាប់ពីបន្ទុកអគ្គិសនីតាមរយៈសំណួរបំផុសរបស់គ្រូបានត្រឹមត្រូវ។
- សិស្សពិសោធពីបន្ទុកអគ្គិសនីបានត្រឹមត្រូវតាមរយៈការងារក្រុម។
- មានស្មារតីប្រុងប្រយ័ត្នចំពោះការប្រើប្រាស់អគ្គិសនីអោយបានជាប្រចាំ។

II–  សម្ភារ

- ក្រដាសកាម ស្កុត ហ្វីត កែវជ័រ សន្លឹក អាលុយមីញ៉ូម (AL) សន្លឹកកិច្ចការ បំពង់ទីបទឹក ស្អាតជ័រ អំពូលភ្លើង រោមសត្វ ក្រណាត់ ឬក្រដាសអនាម័យ...។

III–  លំនាំនៃការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| . ពិនិត្យអនាម័យ<br>. ពិនិត្យអវត្តមាន | ជំហានទី១(២នាទី)<br>ស្ថេរភាពថ្នាក់ | សិស្សច្បងរាយការណ៍ |
| . នៅពេលចំហេះ C និង $O_2$ តើអាតូម C និង $O_2$ បាត់បង់ដែរឬទេ?<br>. ចូរសរសេរសមីការតាងប្រតិកម្ម គីមីចំហេះ C និង $O_2$<br>. តើអ្នកប្រើប្រាស់អ្វីសម្រាប់បំភ្លឺផ្ទះរបស់អ្នកនៅពេលយប់? | ជំហានទី២(៥នាទី)<br>រំលឹកមេរៀនចាស់<br>. ចំហេះ C និង $O_2$<br>អាតូម C និង $O_2$ ត្រូវបានរក្សា<br>$C + O_2 \longrightarrow CO_2$<br>. ចង្កៀង ទៀន អំពូលភ្លើង | . សិស្សឆ្លើយតាមរយៈសមត្ថភាពមានស្រាប់។<br>. សរសេរសមីការលើក្រដាស់ជាបុគ្គល<br>. ចង |
| . តើអំពូលភ្លើងភ្លឺដោយសារអ្វី?<br>. ចែកសិស្សជាក្រុម | ជំហានទី៣(៣០នាទី)<br>មេរៀនថ្មី: សញ្ញាណអគ្គីសនី "បន្ទុកអគ្គីសនី" | . គ្រូគួរតែសួរសិស្សបន្ថែមទៅលើបំពង់ទីបថាវាអាចចម្លងចរន្តអគ្គីស |

| | | |
|---|---|---|
| . ចូរសង្កេត<br>. គ្រូយកបំពង់ទីបត្រដុស និង ក្រដាសអនាម័យ។<br>. ហេតុអ្វីបានជាគ្រូដាក់បំពង់ទីប នេះជិតវត្ថុស្រាលៗ<br>(រោមសត្វ ជ័រស្តោត) ឆក់? | . បំពង់ទីបត្រដុសរួច ដាក់ជិតរោម សត្វ ឆក់ដក់ជិត ជ័រស្តោត ឆក់ ព្រោះបំពង់ទីបមានបន្ទុកអគ្គីសនី។ ដូចនេះ | នីដែរឬទេ<br>• មេដែកដែរឬទេ<br>• ប្រើជាអ៊ីសូឡង់ |
| តើបន្ទុកអគ្គីសនី កើតមាននៅពេលណា? | | |
| សម្មតិកម្ម គួរតែអោយសិស្សក្រុម នីមួយៗ រាយការពីវិធីរបស់ពួកគេ<br>. ចែកសន្លឹកកិច្ចការ<br>. ចែកសម្ភារ និងធ្វើពិសោធ<br>. អោយសិស្សសរសេរលទ្ធផលលើ សន្លឹកកិច្ចការ<br>. អោយសិស្សធ្វើពិសោធ<br><br>. សរសេរលទ្ធផល និងរាយការណ៍<br>. ធ្វើពិសោធបន្ត<br>. សរសេរលទ្ធផល និងរាយការណ៍<br>. ធ្វើពិសោធទី៤<br>. សរសេរលទ្ធផល និងរាយការណ៍<br><br>. ចូរទាញសេចក្តីសន្និដ្ឋាន<br>. គ្រូអោយសិស្សសន្និដ្ឋាន | . ធ្វើពិសោធតាមរូបភាពទី១ (ក្នុង សន្លឹកកិច្ចការ)<br>. សក់ឆក់បំពង់ទីប<br><br>. ធ្វើពិសោធ តាមរូបភាពទី២ (ក្នុងសន្លឹកកិច្ចការ)<br>. រោមសត្វឆក់បំពង់ទីប<br>. ពិសោធរូបទី៣<br>. ឆក់ដៃ<br>. ពិសោធរូបទី៤<br>. ពិសោធតាមរូបភាពទី៤<br>. អំពូលភ្លើងភ្លឺ<br>សន្និដ្ឋានៈ<br><u>បន្ទុកអគ្គីសនីកើតមាននៅពេលអង្គធាតុពីរកកិតគ្នា។</u> | . អនុវត្តការពិសោធរូបទី១<br><br>. រាយការណ៍លទ្ធផល<br><br>. អនុវត្តការពិសោធរូបទី២<br><br>. សិស្សរាយការណ៍<br>. ធ្វើពិសោធរូបភាពទី៣<br>. រាយការណ៍<br>. ធ្វើពិសោធរូបភាពទី៤<br>. រាយការណ៍<br><br>. សេចក្តីសន្និដ្ឋានតាមក្រុម |
| . ក្នុងធម្មជាតិ តើផ្គរ ផ្លេកបន្ទោរ កើតឡើងដោយសារអ្វី? | ជំហានទី៤(៦នាទី)<br><u>ស្ពាទិច</u><br>. ពេលព្យុះ ភ្លៀង ខ្យល់ និងពពក បក់ប៉ះគ្នា (កកិតគ្នា) បណ្តាលអោយកើតនូវផ្លេកបន្ទោរ ផ្គរ រន្ទះ។ | . សិស្សឆ្លើយតាមរយៈការយល់ពីខ្លឹមសារមេរៀន (ជាបុគ្គល) |

| | | |
|---|---|---|
| . ក្នុងជីវភាពរស់នៅប្រចាំថ្ងៃដើម្បីជៀសវាងការគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់អគ្គីសនី តើអ្នកត្រូវធ្វើដូចម្តេចខ្លះ? | ជំហានទី៥ (៥នាទី)<br>. ជៀសវាងគ្រោះថ្នាក់ត្រូវះ<br>. មិនត្រូវយកដៃទៅស្ទាប នៅកន្លែងដែលមានចរន្ត<br>. មិនត្រូវប៉ះពាល់<br>. បណ្តាំផ្ញើ | |

## សន្លឹកកិច្ចការទី១

សំណួរគន្លឹះ៖ តើបន្ទុកអគ្គិសនីកើតមាននៅពេលណា?

១. ចូលឆ្លើយ និងសំណួរខាងលើ

..........................................................................................

..........................................................................................

..........................................................................................

តើធ្វើដូចម្ដេច ដើម្បីដឹងថាវាមានបន្ទុកអគ្គិសនី?

..........................................................................................

..........................................................................................

..........................................................................................

២. ចូររៀបរាប់សម្ភារពិសោធន៍

..........................................................................................

..........................................................................................

..........................................................................................

៣. ដំណើរការពិសោធន៍

១)




- ត្រដុសបំពង់ជ័រជាមួយក្រដាស់ ២០ ទៅ៣០ ដង រួចដាក់ជិតសក់នាំអោយ

..........................................................................................

២)




- ត្រដុសខាងលើ រួចដាក់ជិតរោមសត្វនាំឲ្យ

..........................................................................................

# សន្លឹកកិច្ចការទី២

ពិសោធន៍ទី៣ និងទី៤




- យើងត្រដុសបំពង់ជ័រ (បំពង់ទីប) និងក្រដាស់ពី២០ ទៅ ៣០ដង នាំអោយមានបន្ទុកអគ្គិសនី នៅក្នុងកែវជ័រ។
    - រូបភាពទី៣៖ យកដៃទាំងពីរទៅកាន់ (ដូចរូបទី៣)

នាំអោយយើង..........................................................................................................................។

- 
    - រូបភាពទី៤៖ យកដៃម្ខាងកាន់កែវជ័រ ដៃម្ខាងទៀតកាន់អំពូលភ្លើង (ដូចរូបភាពទី៤) នាំឲ្យអំពូលភ្លើង..........................................................................................................................
..........................................................................................................................។

៤. តាមរយៈការពិសោធខាងលើ នាំអោយយើង

សន្និដ្ឋាន៖ បន្ទុកអគ្គីសនីកើត..........................................................................................

..........................................................................................................................។

## យោបល់ និងសំណូមពរ

ចំណុចល្អ
– មានទំនាក់ទំនងមេរៀនចាស់ទៅមេរៀនថ្មី
– មានសម្ភារៈបង្រៀនគ្រប់គ្រាន់
– សិស្សធ្វើសកម្មភាពតាមក្រុម
– គ្រូដើរពិនិត្យសកម្មភាពតាមក្រុមរបស់សិស្ស
– សំយោគកិច្ចការរបស់សិស្សក្រោយពីពិសោធន៍ហើយ ។
– សកម្មភាពប្រព្រឹត្តទៅតាមលំដាប់លំដោយ
– ទុកពេលឲ្យសិស្សពិសោធន៍បានលទ្ធផល
– សិស្សមានភាពសប្បាយរីករាយ
– បង្ហាញសម្ភារៈពិសោធន៍
– សិស្សធ្វើសន្និដ្ឋាន និងសរសេរលើក្ដារខៀន
– សិស្សមានរៀនរកបែបវិទ្យាសាស្ត្រ
– សិស្សបានរិះរកស្វែងយល់លើសំនួរគន្លឹះ តាមរយៈការធ្វើពិសោធន៍ជាក់ស្ដែង ដោយខ្លួនឯង
– សិស្សបំពេញសន្លឹកកិច្ចការ
– បន្ទុកអគ្គិសនីកើតឡើងដោយសារកំលាំងកកិត ឬត្រដុសរវាងអង្គធាតុ 2។
– ណែនាំពីបំរាមទាក់ទងនិងជីវភាពរស់នៅរបស់សិស្ស
– មានការបង្ហាញបញ្ញាតនៃការពិសោធន៍បានច្បាស់លាស់ត្រឹមត្រូវ
– ការបង្កើតសម្មតិកម្មបានល្អស្រួលយល់
– មានការបង្កើតសម្ភារៈពិសោធន៍
– សិស្សបានបង្កើតសម្មតិកម្មនិងការពិសោធន៍ដោយខ្លួនឯងសង្កេតកត់ត្រា លទ្ធផលនៃការពិសោធន៍។
– ណែនាំឲ្យសិស្សមានបំរុងប្រយ័ត្ននិងតំហែរក្សាសម្ភារៈ
– តំណាងក្រុមឡើងសរសេរការសន្និដ្ឋានរបស់សិស្ស
– គ្រូណែនាំឲ្យសិស្សដឹងពីបាតុភូតផ្លេកបន្ទោរ រន្ទះ ក្នុងធម្មជាតិ ។
– គ្រូបានប្រើសំនួរទំនាក់ទំនងមេរៀនៈ ធ្វើពិសោធន៍សិស្សសង្កេត មានសំនួរគន្លឹះ សរសេរសលើក្ដារខៀន ចែកសន្លឹកកិច្ចការ ឲ្យសិស្សសរសេរ សម្មតិកម្មលើសន្លឹក កិច្ចការ ឲ្យសិស្សរាយការណ៍ ឲ្យសិស្សធ្វើការពិសោធន៍ និងទទួលបានជោគជ័យ ។
– មានកិច្ចតែងការបង្រៀននិងបានកំណត់វត្ថុបំណងបានច្បាស់លាស់
– ខ្លឹមសារមេរៀនទាក់ទងទៅនឹងជីវភាពរស់នៅ
– មានកិច្ចតែងការបង្រៀន
– មានការបង្ហាញបាតុភូត (ត្រដុសបំពង់ទីប្បូច យកទៅដាក់ជិតវត្ថុស្រាល)

- មានសកម្មភាពរស់រវើកក្នុងថ្នាក់រៀន
- ចម្លើយរបស់សិស្សទាក់ទងការសង្កេត
- ការបង្រៀនបានសម្រេចតាមវត្ថុបំណង
- គ្រូបានបង្ហាញបាតុភូតងាយៗរួចដាក់សំនួរគន្លឹះឲ្យរិះគិត ដោយដាក់កិច្ចការឲ្យ
សិស្សធ្វើពិសោធន៍ ដោយបញ្ជាក់ទាញរកសេចក្តីសន្និដ្ឋានថា: "តើបន្ទុកអគ្គិសនី មាននៅពេលណា?"
- ការចោទសួរបានត្រឹមត្រូវល្អតាមលក្ខណៈបែបរិះរក
- មានសំនួរកិច្ចការផ្ទះឲ្យសិស្សធ្វើ

ចំណុចកែលំអ
- គួរតែឲ្យសិស្សពិនិត្យមើលបំពង់ទីបមុនពេលពិសោធន៍ ថាតើវាមានបន្ទុកអគ្គិសនី ឬមួយអត់ ។
- មិនត្រូវឲ្យសិស្សយកដៃទៅកាន់បន្ទុកអគ្គិសនីទេ ។
- បើខ្ញុំជាលោកគ្រូ ខ្ញុំនឹងព្យាយាមធ្វើយ៉ាងណា ដើម្បីបំផុសឲ្យសិស្សបានធ្វើប្លង់ពិសោធន៍ដោយខ្លួនឯង បន្ថែមទៀតរួចប្រមូលមតិ និងធ្វើការសំយោគ ដើម្បីបានប្លង់ពិសោធន៍មួយដែលជាកំរិតរបស់សិស្ស ។ ហើយគួរលុបចោលដំណើរការ ពិសោធន៍នៅក្នុងសន្លឹកកិច្ចការ រួចទុកចន្លោះទំនេរដើម្បីឲ្យសិស្ស រៀបរាប់តាម គំនិតរបស់គេរួច
- គួរសរសេរប្លង់ពិសោធន៍ក្នុងកិច្ចតែងការ
- មុនធ្វើការពិសោធន៍ គួរយកបំពង់ទីបមិនទាន់ត្រដុសមកដាក់លើកំទេចក្រដាសស្តើង ។ តើវាមានបន្ទុក អគ្គិសនីរីទេ ?
- សូមកំណត់រយៈពេលធ្វីពិសោធន៍
- មុនពេលសិស្សពិសោធន៍ គ្រូគួរណែនាំឲ្យបានច្បាស់ ។
- គ្រូគួរសរសេរសម្មតិកម្មរបស់សិស្សលើក្តារខៀន ដើម្បីធ្វើការផ្ទៀងផ្ទាត់ ។
- គួរបញ្ចូលរូបភាពពិសោធន៍ក្នុងកិច្ចតែងការបង្រៀនក្នុងជំហានទី ៣។
- គួរឲ្យសិស្សរាយការណ៍ឲ្យបានគ្រប់គ្រាន់ពេលបង្រៀន
ការពិសោធន៍មានលក្ខណៈច្បាស់លាស់ជាក់លាក់ហើយ តើគួរមិនបាច់ ឲ្យសិស្សឡើងសរសេរចម្លើយ លើក្តារខៀនឲ្យបានឬទេ ? ព្រោះចម្លើយដូចគ្នាសរសេរចម្លើយដូចគ្នាសរសេរដដែលៗ គួរសរសេរសរុប គំនិតគ្នាតែមួយ ។
- គួរកុំពិសោធន៍បង្ហាញឲ្យសិស្សមើលមុន
- គួរណែនាំពីរបៀបធ្វើពិសោធន៍ដល់សិស្សជាមុនសិន ។
- សូមធ្វើប្លង់ពិសោធន៍ក្នុងតែងការបង្រៀន
- ការធ្វើសំយោគចម្លើយគួរកុំឆ្លើយថាត្រូវ នាំឲ្យក្រុមដទៃទៀតលែងហ៊ានឡើងឆ្លើយ ឬកែកំហុសដែល ក្រុមខ្លួនរកឃើញ ។
- សូមឲ្យសម្ភារៈឧបទ្ទេសក្នុងការបង្រៀនមានច្រើនសំរាប់ឲ្យសិស្សធ្វើពិសោធន៍

- ត្រង់ចំណុចរំឭកមេរៀនចាស់គួរតែឲ្យសិស្សម្នាក់ឡើងសរសេរសមីការនៅ លើក្តារខៀន ។
- ប្រសិនជាខ្ញុំបង្រៀនវិញ កិច្ចតែងការបង្រៀន នៅត្រង់ខ្ទង់សកម្មភាព សិស្សខ្ញុំនឹងសរសេរឲ្យបានច្បាស់លាស់ពីសកម្មភាពនេះ ដោយបញ្ជាក់ពីលក្ខខណ្ឌ ។
- នៅជំហានទី2 រំលឹកមេរៀនចាស់ ប្រសិនជាខ្ញុំបង្រៀនវិញ នៅពេលឲ្យសិស្ស
សរសេរសមីការរួម គួរលោកគ្រូហៅសិស្សម្នាក់ឲ្យមកសរសេរលើក្តារខៀន ដើម្បីធ្វើកំណែរួម ។
- ពេលក្រុមណាមួយធ្វើការពិសោធន៍ មិនដល់គោលដៅ គួរឲ្យក្រុមផ្សេងធ្វើពិសោធន៍ មិនដល់គោលដៅ គួរឲ្យក្រុមផ្សេង ធ្វើពិសោធន៍បង្ហាញវិញ ប្រសើរ ជាងគ្រូធ្វើបង្ហាញ ។
- គួរឲ្យសិស្សបង្ហាញលទ្ធផលពិសោធន៍គ្រប់មុខ (បង្ហាញបានតែ1ក្រុម )
- គួរលើកទឹកចិត្តសិស្សដែលច្នៃរកសម្ភារៈពិសោធន៍ផ្សេងពីគ្រូ (ដូចជាយកដៃកាតស្រុះ)
- ពេលគ្រូឲ្យសិស្សបំពេញសន្លឹកកិច្ចការហើយ គួរតែដើរត្រួតពិនិត្យដឹងឮឲ្យផ្តល់ចំលើយជូន ។

# កិច្ចតែងការបង្រៀន

មុខវិជ្ជា: វិទ្យាសាស្ត្រអនុវត្ត

មេរៀន: កំណកញើស

រយៈពេល: ១ម៉ោង

I/ វត្ថុបំណង:

ចំណេះដឹង:សិស្សប្រាប់បានពីកំណាញើសដែលកើតឡើងលើផ្ទៃនៃកែវដែលមានដាក់ទឹកកកបានត្រឹមត្រូវតាមរយៈរូបភាព និងសំណួរបំផុស។

បំណិន: សិស្សបកស្រាយបានពីកំណាញើសបានត្រឹមត្រូវតាមរយៈការពិសោធន៍ និងពិភាក្សាក្រុម។

ឥរិយាបថ: សិស្សទម្លាប់យកចិត្តទុកដាក់ និងមានការស្រាវជ្រាវអំពីការពិសោធន៍ងាយៗទាក់ទងជីវភាពរស់នៅ។

II/ សម្ភារ:

ទឹក ទឹកកក កែវជ័រពីរ សន្លឹកអាលុយមីញ៉ូម សន្លឹកកិច្ចការ រូបភាព។

III/ ដំណើកនាំមេរៀន:

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . អវត្តមាន<br>. សណ្តាប់ធ្នាប់<br>. អនាម័យ | <u>ជំហានទី១</u><br>. អវត្តមាន<br>. សណ្តាប់ធ្នាប់<br>. អនាម័យ | ប្រធានថ្នាក់រាយការណ៍ |
| . តើភាពរូបនៃទឹកមានប៉ុន្មានប្រភេទ?<br>. ប្អូនធ្លាប់ដាំទឹកដែរឬទេ?<br>. ពេលទឹកពុះឃើញឃើញមានអ្វីនៅលើគម្របកំសៀវ?<br>. ពេលចំហាយទឹកក្លាយជាទឹករាវហៅថាអ្វី? | <u>ជំហានទី២</u><br><u>រំលឹកមេរៀនចាស់</u><br>រាវ រឹង ឧស្ម័ន0<br><u>មេរៀនទំនាក់ទំនង</u><br>. ធ្លាប់<br>. ចំហាយទឹក<br>. កំណាញើស | . សិស្សឆ្លើយជាបុគ្គល<br>. ឆ្លើយជាបុគ្គល<br>. ឆ្លើយជាបុគ្គល<br>. ឆ្លើយជាបុគ្គល |

| | | |
|---|---|---|
| ប្រើប័ណ្ណពាក្យ<br>ចំហាយទឹក<br>ទឹករាវ<br>ទឹកកក<br>ទឹករាវ | <u>ជំហានទី៣</u><br><u>មេរៀនថ្មី: កំណកញើស</u><br> | . សិស្សសង្កេត និងឆ្លើយ |
| . សួរសំណួរបំផុសពីការបំផ្លែងភាពរូបនៃទឹកដោយបិតជារង្វង់លើក្តារខៀនភ្ជាប់ប័ណ្ណពាក្យនិមួយៗដោយសញ្ញាព្រួញ។ | គំនូសតាងនៃការបំបែកនៃទឹក | |
| . តើការប្រែប្រួលភាពរូបពីទឹកកកទៅរាវហៅថាអ្វី? | | . ឆ្លើយជាបុគ្គល<br>▪ការរលាយ |
| . តើការប្រែប្រួលភាពរូបពីរាវទៅចំហាយហៅថាអ្វី? | | ▪រំហួត |
| . តើការប្រែប្រួលភាពរូបពីចំហាយទៅរាវហៅថាអ្វី? | | ▪កំណកញើស |
| . ចុះពីរាវទៅកកវិញហៅថាអ្វី? | | ▪កំណក |
| . គ្រូបង្ហាញកែវទឹកពីរ | ដាក់ទឹក $\frac{1}{3}$ នៃកែវ | . សិស្សសង្កេត |
| . តើប្អូនសង្កេតឃើញអ្វីនៅផ្ទៃកែវទាំងពីរ? | . ទឹកធម្មតា<br>. ទឹកកក<br>. ទឹកធម្មតាមិនប្រែប្រួល<br>. ទឹកកក: មានកំណញើស ទឹកស្អាប់បន្តិច | .សិស្សពិភាក្សាប៉ានស្មានចម្លើយ ៥នាទី<br>. សិស្សផ្តល់ចម្លើយ |

| | | |
|---|---|---|
| សំណួរគន្លឹះ: | តើទឹកនៅលើផ្ទៃកែវបានមកពីណា? | |
| . ចែកសិស្សជា៤ក្រុម | . ចំហាកត្រជាក់ទឹកកកប៉ះខ្យល់បរិយាកាស។ | . សិស្សពិភាក្សា ប៉ានស្មានចម្លើយ ៥នាទី |
| . គ្រូសរុបចម្លើយបាន់ស្មាន<br>. តើប្អូនត្រូវធ្វើដូចម្តេចដើម្បីអោយដឹងថាការប៉ាន់ស្មានណាមួយត្រឹមត្រូវ? | | . ទឹកជ្រាបតាមផ្ទៃកែវ<br>. ទឹកជ្រាបតាមមាត់កែវ<br>. សិស្សឆ្លើយត្រូវធ្វើពិសោធ |
| . តើត្រូវរៀបចំប្លង់ពិសោធន៍ដូចម្តេច? សម្ភារៈអ្វីខ្លះ? | | . សិស្សពិភាក្សាក្រុម រាយការណ៍ពីប្លង់ពិសោធ |
| . ឥឡូវនេះគ្រូណែនាំប្អូនទៅរកការពិសោធន៍មួយ:<br>គ្រូមានកែវ ថង់ប្លាស្ទិច ទឹកកក | <u>ពិសោធន៍ទី១</u><br><br> | . សិស្សស្តាប់ការណែនាំ និងធ្វើពិសោធ |
| . ក្នុងការសង្កេតពិសោធលើកទី១ យើងសង្កេតឃើញអ្វីខ្លះ? | លទ្ធផលពិសោធទី១<br>. មានកំណាញើសជុំវិញផ្ទៃកែវ | |
| . តើទឹកដែលប្អូនបានឃើញ ជាទឹកដែលជ្រាបតាមផ្ទៃកែវ ឬយ៉ាងណា?<br>គ្រូណែនាំប្អូនទៅរក ការសោធន៍មួយទៀត | | តំណាងក្រុមរាយការណ៍<br>. មានកំណាញើសជុំវិញផ្ទៃកែវ<br>. ទឹកជ្រាបតាមមាត់កែវ<br>. ទឹកឆ្លងកាត់តាមមាត់កែវ |
| . គ្រូយកក្រដាសស្តើងបិតលើកែវហើយបិតក្រដាសអាលុយមីញ៉ូមពីលើតើក្រដាសសើមឬទេ? បើទឹកជ្រាបក្រដាសវាពិតជាសើម | <u>ពិសោធន៍ទី២</u><br><br> | . សង្កេតពិសោធន៍ |
| . តើប្អូនសង្កេតឃើញអ្វីបន្ទាប់ពីបកសន្លឹកអាលុយមីញ៉ូម? | លទ្ធផលពិសោធ:<br>. គ្មានកំណកញើសនៅលើផ្ទៃកែវ | |

<table>
<tr>
<td>. ឆ្លងកាត់តាមការពិសោធន៍ទាំងពីរលើក:<br>តើតំណក់ទឹកបានមកពីណា?<br><br>. គ្រូអោយសិស្សកសាងមេរៀនសង្ខេប</td>
<td>(ក្រោយពេលបកសន្លឹកអាលុយមីញ៉ូម)<br>. ផ្ទៃខាងក្រៅសន្លឹកអាលុយមីញ៉ូម សើមតិចៗ<br>. តំណក់ទឹកមិនបានឆ្លងកាត់តាមផ្ទៃកែវទេ<br>. តំណក់ទឹកមិនជ្រាបតាមមាត់កែវទេ។<br>. ក្រដាសមិនសើមទេ<br>សន្និដ្ឋាន:<br>. កំណកញើសជាចំហាយត្រជាក់នៃទឹកកកប៉ះខ្យល់បរិយាកាសក្លាយជាទឹករាវ។<br><br><u>មេរៀនសង្ខេប:</u><br>តំណក់ទឹកដែលមាននៅលើផ្ទៃកែវគឺជាទឹករាវ។ទឹករាវនេះបានមកពីចំហាយទឹកក្នុងខ្យល់បរិយាកាសដែលគេមិនអាចមើលឃើញហៅថាកំណកញើស។</td>
<td>. កត់ត្រាលទ្ធផលពិសោធន៍<br><br>. សិស្សធ្វើការសន្និដ្ឋាន<br>. តំណាងក្រុមរាយការណ៍<br><br>. សិស្សកសាងមេរៀនសង្ខេបដោយខ្លួនឯង។</td>
</tr>
<tr>
<td>. គ្រូបង្ហាញផ្ទាំងរូបភាពវដ្តទឹកអោយសិស្សសង្កេត</td>
<td><u>ជំហានទី៤</u><br><table><tr><td>១</td><td>២</td><td>៣</td></tr><tr><td>រំហួត</td><td>កំណកញើស</td><td>ការជ្រាបចូលក្នុងដី</td></tr></table></td>
<td>. សិស្សសង្កេតផ្ទាំងរូបភាព និងពិភាក្សាក្រុម<br>. តំណាងក្រុមរាយការណ៍</td>
</tr>
<tr>
<td>. បើប្អូនកំពប់អំបិលនៅលើដីខ្សាច់<br>. តើប្អូនធ្វើដូចម្តេចទើបបានអំបិលមកវិញ?</td>
<td><u>ជំហានទី៥</u><br>. កិច្ចការផ្ទះ:</td>
<td>. សិស្សស្រាវជ្រាវនៅផ្ទះ:</td>
</tr>
</table>

## សន្លឹកកច្ចការ

១ / ចូរបង្ហាញគំនូសតាងនៃការបំប្លែងភាពរូបនៃទឹក




- ចូរបំពេញត្រង់សញ្ញាព្រួញគំនូសតាងបំប្លែងរូបភាពនៃទឹក

២/ ចូរធ្វើការសង្កេត តើមានអ្វីខុសគ្នារវាងកែវទឹកទាំងពីរ?
(ទឹក $\frac{1}{3}$ នៃកែវ)

- កែវដែលមានដាក់ទឹកកក......................................................

- កែវដាក់ទឹកធម្មតា..................................................................

**សំណួរគន្លឹះ៖ តើដំណក់ទឹកនៅលើផ្ទៃកែវបានមកពីណា?**

☞ ចូលប្អូនធ្វើការទស្សន៍ទាយ

..........................................................................................................

..........................................................................................................

៣/ ចូលប្អូនប្រាប់ពីប្លង់ពិសោធ និងសម្ភារៈ

..........................................................................................................

..........................................................................................................

៤/ ដំណើរការពិសោធន៍

-ពិសោធលើកទី១




-ពិសោធលើកទី២




លទ្ធផលពិសោធលើកទី១

............................................

............................................

លទ្ធផលពិសោធលើកទី២

..............................................

..............................................

៥/ វិភាគ និងសន្និដ្ឋាន...............................................................

..........................................................................................................

..........................................................................................................

## យោបល់ និងសំណូមពរ

ចំណុចល្អ
- បានផ្សារភ្ជាប់ខ្លឹមសារចាស់ទៅខ្លឹមសារមេរៀនថ្មី
- គ្រូមានសំណួរគន្លឹះ
- បង្រៀនតាមលំនាំវិទ្យាសាស្ត្រ
- ផ្តល់ឱកាសឲ្យសិស្សរៀនតាមបែបរិះរក
- គ្រូមានសម្ភារៈ គ្រប់គ្រាន់សំរាប់ធ្វើពិសោធន៍
- ការបង្រៀនសម្រេចតាមវត្ថុបំណង
- សិស្សមានភាពសប្បាយរីកក្នុងការរៀនសូត្រ
- ការបង្រៀនមានសំណួរទំនាក់ទំនងទៅនិងខ្លឹមសារបន្តបន្ទាប់
- សិស្សបានធ្វើសន្និដ្ឋានលើការពិសោធន៍
- ដំណើរការតាមលំដាប់លំដោយ
- មានការបង្ហាញបាតុភូតកំណកញើស
- ដាក់បញ្ហា បង្កើតសម្មតិកម្ម ធ្វើការពិសោធន៍
- រាយការណ៍ទៅលើលទ្ធផលពិសោធន៍
- គ្រូសំយោគសេសចក្តីសន្និដ្ឋានទៅលើខ្លឹមសារមេរៀន
- សកម្មភាពសិស្ស–គ្រូសបតាមខ្លឹមសារ
- មានកិច្ចតែងការ និងបានកមណត់វត្ថុបំណងច្បាស់លាស់
- បានឲ្យសិស្សបានបង្កេតនិងអនុវត្តផ្ទាល់
- គ្រូប្រើប័ណ្ណពាក្យមានសម្ភារៈបង្រៀនគ្រប់គ្រាន់
- លើកទឹកចិត្ត
- មានបណ្តាំផ្ញើ
- ការបែងចែកក្រុមសិស្សតាមប័ណ្ណពណ៌ មានល្បែងសិក្សា (សិស្សសប្បាយរីករាយ) ។
- សិស្សយល់ពីវដ្តរបស់ទឹក
- សិស្សយល់ពីទឹកគួរបរិភោគនិងមិនគួរបរិភោគ

ចំណុចកែលម្អ
– ចំពោះការសន្និដ្ឋាន: បើរូបខ្ញុំវិញខ្ញុំឲ្យសិស្សទាញសេចក្តីសន្និដ្ឋាន នៅពេលចប់ ពិសោធន៍ទាំងពីរលើក ។
– គួរឲ្យសិស្សពិភាក្សាពីប្លង់ពិសោធន៍
– សូមកុំប្រើសំណួរបំផុសច្រើនពេក
– ជួយកែតំរូវសន្លឹកកិច្ចការ សំណួរទី ១
– សូមអ្នកគ្រូមេត្តាកែអក្ខរាវិរុទ្ធយើងវិញ ដើម្បីជៀសវាងបង្រៀនខុសដោយ ប្រយោលទៅដល់ (សំនើម, រឺ) នៅលើក្តារខៀន។
– ព្រួញនៃសន្លឹកកិច្ចការបញ្ច្រាស
– ការទាញសេចក្តីសន្និដ្ឋាន: បើខ្ញុំវិញទាញសេចក្តីសន្និដ្ឋានពេលចប់ពិសោធន៍ទាំងពីរលើក ។
– គួរកំណត់ពេលឲ្យបានច្បាស់សំរាប់ពិភាក្សាក្រុម
– គួរបង្ហាញបំរុងប្រយ័ត្នសិស្សឲ្យបានច្រើនថែមទៀត
– គួរបញ្ជាក់បន្ថែមទៅលើចំលើយនៅក្នុងខ្លឹសារនៃសំណួរគ្រូ ។
– ណែនាំកិច្ចការសង្កេតមិនបានត្រឹមត្រូវ ដូចជាតើតែងមានបិទ AI មានអ្វីកើតឡើង ព្រោះមិនមានពាក្យទឹកកក។
– ពិសោធន៍លើកទី 1 លើកទី 2 មានការច្រឡំគ្នាបន្តិច ។
(គួរតែសម្រួលការពិសោធន៍)
– ពេលសិស្សពិសោធន៍គ្រូគួរដើរពិនិត្យជំរុញសិស្សតាមក្រុម ។

# កិច្ចតែងការបង្រៀន

មុខវិជ្ជា : វិទ្យាសាស្ត្រអនុវត្ត
ថ្នាក់ទី៤
ជំពូក៦ : កម្លាំង និង ចលនា
មេរៀនទី១២: មេដែក
ក.ប៉ូលមេដែក
ខ.ការចង្អុលទិសនៃមេដែក
រយៈពេល :៥០ នាទី

I– វត្ថុបំណង:

- សិស្សប្រាប់បានឈ្មោះប៉ូលទាំងពីររបស់មេដែក និងការចង្អុលទិសរបស់មេដែក តាមរយៈការពិសោធន៍ និងសំណួរបំផុសរបស់គ្រូ។
- សិស្សកំនត់ប៉ូលទាំងពីររបស់មេដែកផ្សេងៗ(របារមេដែក មេដែកឡេវអាវ មេដែកអក្សរអ៊ុយ...) បានតាមការធ្វើពិសោធជាក្រុមបានត្រឹមត្រូវ។
- សិស្សមានទម្លាប់ស្រាវជ្រាវ និងធ្វើពិសោធក្នុងការសិក្សា និងក្នុងជីវភាពរស់នៅ។

II– សម្ភារបង្រៀន:

របាមេដែក មេដែកអក្សរអ៊ុយ មេដែកឡេវអាវ ម្ជុលបារាំង ចានដាក់ទឹក ស្មោរ ទឹក កំទេចដែក ។

III– សកម្មភាពបង្រៀន:

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| • តើយើងអវត្តមានប៉ុន្មាននាក់?<br>• តើក្រុមណាសម្អាតថ្នាក់ថ្ងៃ នេះ? | **ជំហានទី១ (៣នាទី)**<br>• ការត្រួតពិនិត្យអវត្តមាន<br>• ការត្រួពិនិត្យ អនាម័យ | • ប្រធានថ្នាក់ រាយការណ៍ |
| • តើមេដែកជាអ្វី?<br><br>• តើមេដែកមានទម្រង់ដូចម្តេចខ្លះ? | **ជំហានទី២ (៨នាទី)**<br>(រំលឹកមេរៀនចាស់)<br>• និយមន័យមេដែក ជាដុំដែករឺលោហៈធាតុ ដែល អាចឆក់ឬស្រូប ដែកបាន។<br>• ទម្រង់នានារបស់មេដែក<br><br>**ទំនាក់ទំនងមេរៀន**<br>• កំលាំងស្រូបរបស់ មេដែក | • ជាដុំដែករឺលោហៈធាតុដែល អាចឆក់ឬស្រូប<br>• ដែកបាន។<br><br>• មេដែកមានទម្រង់ជា របា មេដែក មេដែកអក្សរអ៊ុយ មេដែករាងជាចិញ្ចៀន ផ្កាយ មេដែក មេដែកឡេវអាវ...។ |

<table>
<tr>
<td>• បើយើងយកកំទេចដែកដាក់ព្រាយក្រដាសហើយយករបារមេដែកដាក់ថ្នមៗពីលើយើងឃើញអ្វីកើតឡើង?</td>
<td></td>
<td>• មេដែកស្រូបទាញ កំទេចដែកជាប់នៅលើមេដែក។</td>
</tr>
<tr>
<td>• តើកំទេចដែកស្រូបជាប់នៅ ផ្នែកណាខ្លះនៃមេដែកច្រើនជាងគេ?<br>• ឲ្យសិស្សទស្សន៍ទាយ<br>• ចែកសម្ភារ របារមេដែក កំទេចដែក និងក្រដាស។<br>• គ្រូសរុប<br>• បិតសំណួរគន្លឹះ</td>
<td>ជំហានទី៣ (៣៥នាទី)<br>មេរៀនប្រចាំថ្ងៃ<br>មេដែក<br>២.ប៉ូលមេដែក<br>ក.កំណត់ប៉ូលមេដែក<br>• ផ្នែកនៃមេដែកអាចស្រូបយកម្ជុលបាវាំងឬកំទេចដែក<br>រូបភាពទី១<br><br>រូបភាពទី២<br><br>រូបភាពទី៣<br><br>• ចុងសងខាងនៃមេដែកជាប់កំទេចដែកច្រើនជាងគេហៅថាប៉ូលមេដែក។</td>
<td>• កំទេចដែកជាប់នៅលើមេដែកច្រើននៅចុងសងខាងនៃមេដែក។<br>• ចំលើយដាក់ស្លេង<br>• សិស្សធ្វើពិសោធ អង្កេត និងរាយការណ៍។<br>• សិស្សស្តាប់ និងអង្កេតដោយយកចិត្តទុកដាក់។</td>
</tr>
<tr>
<td colspan="3">តើមេដែកមានប៉ូលប៉ុន្មាន? អ្វីខ្លះ? ហើយគេកំណត់ប៉ូលរបស់មេដែកបានយ៉ាងដូចម្តេច?</td>
</tr>
<tr>
<td>• ចែកសិស្សជាក្រុម<br>• ឲ្យសិស្សទស្សន៍ទាយ<br>• អោយសិស្សរៀបចំប្លង់ពិសោធន៍ដោយប្រើប្រាស់សម្ភារៈ របារមេដែក ចានដាក់ទឹក ចានស្នោរ។<br>• បង្ហាញសម្ភារនិងប្រាប់ពីបម្រុងប្រយ័ត្នក្នុងការធ្វើពិសោធន៍<br>• អោយសិស្សធ្វើពិសោធ<br>• អោយសិស្សបង្ហាញលទ្ធផលពិសោធន៍</td>
<td>ខ.ការចង្អុលទិសនៃមេដែក<br><br>• ការធ្វើពិសោធ<br></td>
<td>• សិស្សអង្គុយតាម ក្រុម<br>• ចំលើយដាក់ស្លេង<br>• សិស្សរៀបចំប្លង់ពិសោធន៍ដោយគូររូបភាពដាក់លើក្រដាស។<br>• សិស្សស្តាប់អង្កេតដោយយកចិត្តទុកដាក់។<br>• សិស្សធ្វើពិសោធតាមក្រុម។<br>• តំនាងក្រុមបង្ហាញ</td>
</tr>
</table>

<table>
<tr>
<td>

- គ្រូសំយោគ
- ពេលយើងឆ្កូតចុងស្រួចនៃម្ជុលបាំងលើប៉ូលខាងជើងនៃមេដែកហើយដោតជាប់នឹងស្មោរតើពេលយើងដាក់ ក្នុង ទឹកតើចុងស្រួចនោះងាកទៅ ទិសខាងណា?
- ឲ្យសិស្សទស្សន៍ទាយ
- អោយសិស្សធ្វើពិសោធ
- ឲ្យសិស្សបង្ហាញលទ្ធផល
- គ្រូសរុប
- ពេលយើងឆ្កូតចុងស្រួចនៃម្ជុលបាំងលើមិខកាត់ណាមួយនៃមេដែកឡេវអោរហើយដោតជាប់នឹងស្មោរតើពេលយើងដាក់ ក្នុងទឹកតើចុងស្រួចនោះ ងាកទៅ ទិសខាងណា?
- ចែកមេដែកឡេវអោរ និង ម្ជុលបាំង។
- ឲ្យសិស្សទស្សន៍ទាយ
- អោយសិស្សធ្វើពិសោធ
- អោយសិស្សបង្ហាញលទ្ធផលពិសោធន៍។
- គ្រូអោយសិស្សទាញសន្និដ្ឋាន

</td>
<td>

- របារមេដែកមានប៉ូលពីរគឺប៉ូលជើង និងប៉ូលត្បូង។

ប៉ូលមេដែកដែលងាកទៅទិសខាងជើងហៅថាប៉ូលខាងជើងតាងដោយអក្សរ ជ ឬ S។ប៉ូលមេដែកដែលងាកទៅទិសខាងត្បូងហៅថាប៉ូលខាងត្បូងតាងដោយអក្សរ តឬ N។






- ងាកទៅទិសខាងត្បូង



- កំណត់ប៉ូលជើង និងប៉ូលត្បូងមេដែក ឡេវអោរ។



- មេដែកឡេវអោរមានប៉ូលពីរគឺប៉ូលជើងនិងប៉ូល ត្បូង។
- គ្រប់ទម្រង់មេដែកទាំងអស់មានប៉ូលពីរគឺប៉ូលជើង និងប៉ូលត្បូង។

</td>
<td>

របារមេដែកមានប៉ូលពីរគឺប៉ូលជើង និងប៉ូលត្បូង។

- ចំលើយជាក់ស្តែង
- សិស្សធ្វើពិសោធតាមក្រុម។
- ងាកទៅទិសខាងត្បូង
- សិស្សស្តាប់ហើយពិចារណា។
- តំណាងក្រុមមកទទួលសម្ភារ។
- ចំលើយជាក់ស្តែង
- ធ្វើពិសោធតាមក្រុម
- ចំលើយជាក់ស្តែង
- គ្រប់ទម្រង់មេដែកទាំងអស់មានប៉ូលពីរគឺប៉ូលជើង និងប៉ូលត្បូង។
- 

</td>
</tr>
</table>

| | | |
|---|---|---|
| • ចែកមេដែករាងអក្សរអ៊ុយ<br>• អោយសិស្សកំណត់ប៉ូលជើង និងប៉ូលត្បូងរបស់មេដែក រាងអក្សរអ៊ុយ។ | **ជំហានទី៤(4នាទី)**<br><br>• មេដែក រាងអក្សរអ៊ុយមាន ប៉ូលពីរគឺជើង និងប៉ូលត្បូងរបស់ ។ | • តំណាងក្រុមឡើងទទួលមេដែកអក្សរអ៊ុយ។<br>• សិស្សធ្វើពិសោធតាមក្រុម។ |
| • គ្រូអោយសិស្សស្រាវជ្រាវមេរៀនបន្តនៅទំព័រទី៥៧,៥៨ | **ជំហានទី៥(៣នាទី)**<br>បណ្តាំផ្ញើ<br>• អំពើរាងប៉ូល និងប៉ូល | • សិស្សស្តាប់ហើយកត់ត្រា។ |

# សន្លឹកកិច្ចការ ១

<u>ទស្សន៍ទាយទី១</u>

ចូរគូសរង្វង់នៅក្រោមរូបភាពដែលអ្នកយល់ថាត្រឹមត្រូវ។


ក


ខ


គ

- ចំណុច A និង B នៃមេដែកតើចំណុចណាងាកទៅខាងណាខ្លះ?




**តើមេដែកមានប៉ូលប៉ុន្មាន? អ្វីខ្លះ? ហើយគេកំនត់ប៉ូលរបស់មេដែកបានយ៉ាងដូចម្តេច?**

| |
|---|
| តាមគំនិតរបស់ប្អូន:<br>……………………………………………………………………………………………<br>……………………………………………………………………………………………<br>ដំណើរការពិសោធន៍:<br>……………………………………………………………………………………………<br>…………………………………………………………………………………………… |
| តាមគំនិតរួមក្នុងថ្នាក់:<br>……………………………………………………………………………………………<br>……………………………………………………………………………………………<br>ដំណើរការពិសោធន៍:<br>……………………………………………………………………………………………<br>…………………………………………………………………………………………… |

# សន្លឹកកិច្ចការ ២

<u>សន្លឹកទស្សន៍ទាយទី២</u>

ចូរគូសសញ្ញានៅមុខរូបភាពដែលអ្នកយល់ថាត្រឹមត្រូវ។

បើយើងយករបាមេដែកដាក់ក្នុងចានស្នោរហើយបណ្តែតក្នុងចានទឹក តើប៉ូលមេដែកងាកទៅខាងណា?




◯ក្រហមចង្អុលទិសជើង ខៀវចង្អុលទិសត្បូង　　◯ ក្រហមចង្អុលទិស ត្បូង ខៀវចង្អុលទិសជើង

◯ក្រហមចង្អុលទិស  លិច ខៀវចង្អុលទិស  កើត　　◯ ក្រហមចង្អុលទិស កើត ខៀវចង្អុលទិស លិច

**សន្និដ្ឋាន:** ប៉ូលមេដែកដែលងាកទៅទិស...............ហៅថាប៉ូលខាង.........តាងដោយអក្សរ....................។

ហើយ ប៉ូលមេដែកដែលងាកទៅទិស................ហៅថាប៉ូលខាង .............តាងដោយអក្សរ...............។




ពេលយើងឆ្កូតចុងស្រួចនៃម្ជុលបារាំងលើប៉ូលខាងជើងនៃមេដែកហើយដោតជាប់នឹងស្នោរតើពេលយើងដាក់ក្នុងទឹក តើចុងស្រួចនោះងាកទៅទិសខាងណា?

១. ជើង　　២. ត្បូង　　៣. កើត　៤. លិច

ពេលយើងឆ្កូតចុងស្រួចនៃម្ជុលបារាំងលើប៉ូលណាមួយនៃមេដែករាងឡូវអាវហើយដោតជាប់នឹងស្នោរ ពេលយើងដាក់ក្នុងទឹក តើចុងស្រួចនោះងាកទៅទិសខាងណា?





១. ជើង　　២. ត្បូង　៣. កើត　៤. លិច

សន្និដ្ឋាន

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

## យោបល់ និងសំណូមពរ

ចំណុចល្អ
- សិស្សបង្ហាញពីការទំនាញមេដែក
- ប្រើសំណួរគន្លឹះ តើមេដែកមានប៉ូលប៉ុន្មាន ? អ្វីខ្លះហើយគេកំណត់ប៉ូលរបស់មេដែកបានយ៉ាងដូចម្ដេច
- មានសម្ភារៈពិសោធន៍ទៅតាមរូបរាងរបស់មេដែក
- សិស្សបានចូលរួមពិសោធន៍ទាំងអស់ដោយប៉ូលមេដែក
- សេចក្ដីសន្និដ្ឋានបានត្រឹមត្រូវតាមវត្ថុបំណង
- សិស្សបានធ្វើសកម្មភាពច្រើន
- សិស្សមានភាពសប្បាយរីករាយ ក្រោយពេលរកធ្វើពិសោធន៍រួច
- សិស្សចេះធ្វើការរួមគ្នា
- គ្រូបានបង្ហាញនិងពន្យល់លើកិច្ចការតាមដំណាក់ៗ
- ឲ្យសិស្សពិសោធន៍សាកល្បង ហើយសង្កេតទៅលើមេដែក
- បំផុសសំណួរឲ្យសិស្សបង្កើតសម្មតិកម្ម
- សិស្សបង្កើតប្លង់ពិសោធន៍ បង្ហាញលទ្ធផលនិងទាញសេចក្ដីសន្និដ្ឋាន
- ផ្ដល់ឱកាសឲ្យសិស្សធ្វើសកម្មភាពដោយខ្លួនឯង
- គ្រូសម្របសម្រួលក្នុងក្រុមបានល្អ
- ទំនាក់ទំនងមេរៀន
- សំណួរគន្លឹះ
- រំលឹកមេរៀនចាស់
- ឲ្យសិស្សទស្សន៍ទាយ
- កំណត់ប៉ូលមេដែកឡេវអាវបានដោយកូទម្ពុលបណ្ដែតទឹក
- កាយវិការ និងពាក្យសំដីសមរម្យ
- ប្រើប្រាស់ជំហានទាំង ៥ នៃការបង្រៀន
- បង្រៀននិងរៀនតាមបែបរិះរក
- សិស្សមានការរិះគិតបានច្រើន
- ការបង្រៀនទទួលបានលទ្ធផលល្អ មានកិច្ចតែងការសម្ភារៈគ្រប់គ្រាន់ មាន
ទំនាក់ទំនងមេរៀន បង្កបរិយាកាសថ្នាក់រៀនរីករាយពេលទទួលលទ្ធផល ពិសោធន៍បានសម្រេច ។
- អនុវត្តដំណើរការបង្រៀននិងរៀនតាមបែបរិះរក
- បង្រៀនតាមលំនាំវិទ្យាសាស្ត្រ
- សិស្សកត់ត្រាចម្លើយរបស់គ្រូចូលទៅក្នុងសន្លឹកកិច្ចការ
- បំផុសសំណួរឲ្យសិស្សមានចំងល់
- ការបង្រៀនគោរពពេលវេលាបានសមស្រប ។
- ប្រើសំណួរទំនាក់ទំនង
- ប្រើសំណួរបំផុសទៅសិស្សតាមក្រុម
- បំផុសរកឈ្មោះវត្ថុដែលត្រូវពិសោធន
- ប្រាប់ពីរយៈពេលពិភាក្សា + បង្ហាញការពិសោធន៍

ចំណុចកែលម្អ
- មិនបានកំណត់ម៉ោងលើការពិសោធន៍
- មេដែកឡេអាវ (ដឹងមិនបានច្បាស់អំពីប៉ូលរបស់វា ខាងណាជើង-ត្បូង)
- សូមបង្ហាញសម្ភារៈ មុនឲ្យសិស្សសរសេរដំណើរការពិសោធន៍ ។
- សន្លឹកកិច្ចការ សរសេរមិនតាមលំដាប់លំដោយគ្មានសំណួរគន្លឹះ
- សន្លឹកកិច្ចការរបស់គាត់មានការច្របូកច្របល់បន្តិច ។
- សិស្សមានការពិបាកយល់ដែរ ត្រង់ចំណុចដែលពេលលោកគ្រូដាក់ពិសោធន៍ទី១ ដោយមិនដឹងថា យកកំទេចរីមេដែក ដាក់ចានស្មោក្នុងចានដែក វាបញ្ជាក់ពុំសូវច្បាស់។
- សូមបញ្ជាក់ឲ្យច្បាស់ពីសំណួរ ។
- គ្រូគួរតែសម្របទៅតាមការបង្កើតសម្មតិកម្មរបស់សិស្ស
- ខ្លឹមសារសំខាន់ គួរមានសំណួរគន្លឹះតែមួយ
- សំណួរគន្លឹះរបស់គ្រូទូលំទូលាយពេក
- គួរសរសេរសំណួរគន្លឹះក្នុងសន្លឹកកិច្ចការផង ។
- សូមលោកគ្រូសំយោគចំលើយសិស្សគ្រប់ក្រុមដើម្បីរកចំលើយល្អ ។
- សំណួរគន្លឹះមិនទាន់ច្បាស់លាស់កិច្ចតែងការផ្សេងៗ ក្រដាសសំណួរគន្លឹះផ្សេងៗ
- សំណួរគន្លឹះគួរសរសេរដាក់លើក្រដាសកាតុងធំទើបល្អ
- គួរប្រាប់ពីវិធីរកប៉ូលមេដែកតាមវិធីផ្សេងៗទៀតដែលអាចកំណត់ប៉ូលមេដែកបាន។

ឧ: ការប្រើប្រាស់ជាត្រីវិស័យឬមេដែកដែលគេបានកំណត់ប៉ូលរួចស្រេចហើយ ។

# កិច្ចតែងការបង្រៀន

មុខវិជ្ជា   វិទ្យាសាស្រ្តអនុវត្ត
ជំពូកទី៥ សង្កេតលក្ខណៈនៃរូបធាតុ
មេរៀនទី៩ ដំណើរប្រែប្រួលនៃរូបធាតុ
ថ្នាក់ទី  ៣
រយៈពេល ៤០នាទី

I- វត្ថុបំណង

ចំណេះដឹង សិស្សរៀបរាប់វត្ថុរឹងមួយចំនួនដែលអាចក្លាយជាវត្ថុរាវបានត្រឹមត្រូវ តាមរយៈសំណួរបំផុសរបស់គ្រូ។

បំណិន  សិស្សកំណត់ពីលក្ខខណ្ឌដែលធ្វើអោយមានបម្រែបម្រួលនៃវត្ថុរឹង មួយចំនួនបានត្រឹមត្រូវតាមរយៈការពិភាក្សា និងពិសោធន៍។

ឥរិយាបថ សិស្សមានបំរុងប្រយ័ត្នចំពោះការដាក់វត្ថុរឹងមួយចំនួននៅក្នុង ជីវភាពប្រចាំថ្ងៃ។

II- សម្ភារឧបទ្ទេស

- មានអំបិលម៉ដ្ឋ ទឹកក្តៅ ទឹកត្រជាក់ កែវជ័រ កែវក្រិត ក្រដាស ស្លាបព្រា ស្កុត សីរ៉ាំង ចង្រ្កានហ្គាស ឆ្នាំង។
- សៀវភៅសិស្ស សៀវភៅគ្រូ

III- ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពគ្រូ |
|---|---|---|
| . សំណេះសំណាល<br>. ត្រួតពិនិត្យអនាម័យ អវត្តមាន សណ្តាប់ធ្នាប់ | ជំហានទី១<br>. សំណេះសំណាល<br>. អនាម័យ អវត្តមាន សណ្តាប់ធ្នាប់ | . ស្តាប់ ឆ្លើយ<br>. ប្រធានថ្នាក់រាយការណ៍ និងបញ្ជាក់ពីមយលហេតុ |
| . អោយសិស្សប្រមូលសៀវភៅអោយគ្រូ កែ៣នាក់។<br>. តើរាងកាយគ្រប់ដណ្តប់ដោយសារអ្វី?<br>ហើយមានតួនាទីសម្រាប់ធ្វើអ្វី? | ជំហានទី២<br>. កែកិច្ចការសិស្ស<br>. រំលឹកមេរៀនចាស់ | . សិស្សម្នាក់ឡើងកែលើក្តារខៀន<br>. រាងកាយគ្របដណ្តប់ដោយសារស្បែក ។<br><br>. វាមានតួនាទីការពាររាងកាយកុំអោយមានមេរោគផ្សេងៗជ្រាបចូលបាន។ |

| | | |
|---|---|---|
| . តើអ្នកធ្លាប់ឃើញជម្ងឺអ្វីខ្លះដែលកើតនៅលើស្បែក?<br><br>. តើភាពរូបនៃរូបធាតុមានអ្វីខ្លះ?<br><br>. តើរូបភាពទាំងនោះអាចប្តូរទៅជារូបរាងផ្សេងៗបានដែរឬទេ?<br>. ការប្តូររូបរាងនេះហៅថាអ្វី? | ទំនាក់ទំនងមេរៀនថ្មី<br>រឹង រាវ ឧស្ម័ន<br><br>. អាចប្តូររូបរាងបាន<br><br>. បម្រែបម្រួល | . ជម្ងឺដែលកើតនៅលើស្បែកមានកមស្រែង ភ្លឺ បូស រលាក ដំបៅ...<br><br>. រូបភាពនៃរូបធាតុមាន រឹង រាវ ឧស្ម័ន។<br>. ភាពរូបនៃរូបធាតុអាចប្តូររូបរាងបាន<br>. ការប្តូររូបរាងនេះហៅថា បម្រែបម្រួល |
| . គ្រូសរសេរចំនងជើងដាក់លើក្តារខៀន<br><br>. ចូរប្អូនរៀបពីវត្ថុរឹងដែលប្អូនធ្លាប់ស្គាល់<br>. តើក្នុងចំណោមវត្ថុទាំងនោះវត្ថុណាដែលអាចរលាយបាន | ជំហានទី៣<br>មេរៀនប្រចាំថ្ងៃ<br>មេរៀនទី៩<br>ដំណើរប្រែប្រួលរូបធាតុ<br>I– ពីរឹងទៅរាវ<br>. ដុំថ្ម អំបិល ស្ករសឡេវអាវ គុ...<br><br>. អំបិល ស្ករស | . សង្កេត<br><br>. វត្ថុរឹងមានដុំថ្ម អំបិល ស្ករស ឡេវអាវ គុ<br>. ក្នុងចំណោមវត្ថុទាំងនោះ វត្ថុដែលអាចក្លាយជាវត្ថុរាវបានគឺអំបិល និងស្ករស |
| | **តើធ្វើដូចម្តេចដើម្បីអោយអំបិលងាយរលាយ?** | |
| . ចែកសិស្សជាបួនក្រុម ពិភាក្សាវិភាគ លើសម្មតិកម្ម<br><br>. អោយសិស្សរៀបចំប្លង់ពិសោធ<br><br><br><br>. គ្រូបូកសរុបប្លង់ពិសោធន៍ | . បង្កើតសម្មតិកម្ម<br><br>. ធ្វើប្លង់ពិសោធន៍<br><br><br><br>. ប្លង់ពិសោធន៍ | . សិស្សចូលក្រុម<br>. យកអំបិលដាក់ក្នុងទឹក<br>. យកទៅលាយទឹករួចដាំអោយពុះ<br>. ដំបូងយកកែវពីរ កែវមួយដាក់ទឹក ៥០ម.ល រួចដាក់អំបិលចូល និងកែវមួយទៀតដាក់ទឹកក្តៅចូល ៥០ ម.ល រួចដាក់អំបិលចូល និងសង្កេត។<br>. សិស្សស្តាប់ និងគិត |

| | | |
|---|---|---|
| . ចែកសម្ភារ និងអោយសិស្សធ្វើពិសោធន៍ | ពិសោធន៍ទី១<br>. ដាក់អំបិលបរិមាណស្មើគ្នា ក្នុងកែវទឹកក្ដៅ និងទឹកត្រជាក់។<br>ពិសោធន៍ ទី២<br>. ដាក់អំបិលក្នុងកែវទឹកត្រជាក់ពីរ ហើយមួយកូរ និងមួយទៀតឥតកូរ<br>ពិសោធន៍ ទី៣<br>. អំបិលដាក់ក្នុងកែវវែង និងមួយទៀតខ្លីក្នុងបរិមាណទឹក និងអំបិលដូចគ្នា។<br>ពិសោធន៍<br>. ពិសោធទី១<br>ទឹកអំបិលដូចគ្នា<br><br>ទឹកក្ដៅ ទឹកត្រជាក់<br>. ពិសោធទី ២<br>ទឹកអំបិលដូចគ្នា<br><br>ទឹកក្ដៅ ទឹកត្រជាក់ និងកូរ<br>. ពិសោធទី ៣<br>ទឹកអំបិលដូចគ្នា<br> | . សិស្សទទួលសម្ភារ និងធ្វើពិសោធន៍តាមប្លង់ពិសោធន៍ក្នុងក្រុមនិមួយៗ រួចសង្កេត និងកត់ត្រាលទ្ធផល |

| | | |
|---|---|---|
| អោយសិស្សឡើងរាយការណ៍លទ្ធផលពិសោធន៍<br>គ្រូសំយោគ<br>អោយសិស្សទាញសេចក្ដីសន្និដ្ឋាន<br><br><br><br>. អោយសិស្សអានសេចក្ដីសន្និដ្ឋាន | កែវខ្លី កែវវែង<br>. ឡើងរាយការណ៍ពីលទ្ធផល<br><br><br>. សន្និដ្ឋាន<br>ដើម្បីធ្វើអោយអំបិលងាយរលាយក្នុងទឹកមានដូចជាកំដៅ ការកូរ និងការកកិត។ | . តំណាងក្រុមឡើងរាយការណ៍<br><br><br>. ដើម្បីធ្វើអោយអំបិលងាយរលាយក្នុងទឹកមានដូចជា កំដៅ ការកូរ និងការកកិត<br><br><br>. សិស្សពីរ ឬបីនាក់ឡើងអាន |
| <br><br>. ពេលយើងដាក់អំបិលចូលក្នុងទឹក តើអំបិលបាត់ទៅណា?<br>. តើកត្តាអ្វីខ្លះដែលធ្វើអោយអំបិលងាយរលាយ?<br>. តើយើងទុកដាក់វត្ថុរឹង ស្ករ អំបិល ទឹកកក របៀបណា? | ជំហានទី៤<br>ពង្រឹងចំណេះដឹង<br>. អំបិលរលាយ<br><br>. មានកំដោ ការដូរ និងចម្ងាយនៃការកកិតនៃម៉ូលេគុល<br>. ទុកដាក់កុំអោយប៉ះសំណើម | <br><br>. គឺអំបិលរលាយ<br><br>ដើម្បីឆាប់រលាយមានដូចជា កម្តៅ ការកូរ និងចម្ងាយនៃការកកិត<br>. គួរទុកដាក់កន្លែងគ្មានសំណើម |
| <br>. អោយសិស្សយកសៀវភៅកត់ត្រាមេរៀន និងកត់កិច្ចការផ្ទះ។<br>. ចូរប្អូនសរសេរឈ្មោះវត្ថុរឹងដទៃទៀត ដែលអាចក្លាយជាវត្ថុរាវអោយបានចំនួនប្រាំ។ | ជំហានទី៥<br>បណ្ដាំផ្ញើ<br><br>កិច្ចការផ្ទះ | <br><br><br>. សិស្សកត់ត្រាមេរៀន និងកិច្ចការផ្ទះ។ |

## សន្លឹកកិច្ចការ

**តើធ្វើដូចម្តេចដើម្បីអោយអំបិលឆាយរលាយ?**

១. ចូលរកវិធីដែលអាចធ្វើអោយអំបិលក្លាយជាវត្ថុរាវបាន។

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

២. សិស្សធ្វើការជាក្រុមដើម្បីធ្វើពិសោធន៍បញ្ជាក់

ក. ដាក់អំបិលបរិមាណស្មើគ្នា ក្នុងកែវទឹកក្តៅ និងទឹកត្រជាក់

------------------------------------------------------------

------------------------------------------------------------

ខ. អំបិលដាក់ក្នុងទឹកត្រជាក់ មួយកូរ និងមួយទៀតមិនកូរ

------------------------------------------------------------

------------------------------------------------------------

គ. អំបិលដាក់ក្នុងកែវ ដែលកែវមួយវែង និងកែវមួយទៀតខ្លីក្នុងបរិមាណទឹក និងអំបិលស្មើគ្នា

៣. លទ្ធផលពិសោធន៍

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

៤. សន្និដ្ឋាន

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

## យោបល់ និងសំណូមពរ

| |
|---|
| ចំណុចល្អ<br>- ហ៊ានបញ្ចេញមតិយោបល់<br>- ផ្សារភ្ជាប់ខ្លឹមសារមេរៀនទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។<br>- បានប្រើប្រាស់សំណួរដើម្បីផ្សាភ្ជាប់ទៅនឹងមេរៀនថ្មី+ជីវភាពជាក់ស្ែតង<br>-  ឲ្យសិស្សមានបំរុងប្រយ័ត្ន និងការពារក្នុងការប្រើប្រាស់វត្ថុរឹងក្នុងជីវភាព<br>- មានកិច្ចសហការល្អក្នុងការធ្វើពិសោធន៍<br>- គ្រូចុះជយយសម្របសម្រួលតាមក្រុម ធ្វើឲ្យដំណើរការពិសោធន៍មានភាព សកម្មនិងទលលទ្ធផលល្អ។<br>- ឲ្យសិស្សបង្កើតសម្មតិកម្ម ទស្សន៍ទាយប៉ាន់ស្មាន<br>- សិស្សបានធ្វើការផ្ទៀងផ្ទាត់លទ្ធផលពិសោធន៍<br>- ឲ្យសិស្សទាញសេចក្ដីសន្និដ្ឋានតាមក្រុមនីមួយៗ<br>- សិស្សមានបំរុងប្រយ័ត្នស្ដាប់<br>-  កិច្ចការផ្ទះ<br>-   កំណត់រយៈពេលពិភាក្សា |
| ចំណុចកែលម្អ<br>- គួរនិយាយឲ្យបានខ្លាំងជាងនេះបន្តិច<br>- ពេលនិយាយគួរផ្ដោតអារម្មណ៍ទៅលើសិស្ស<br>- ពេលធ្វើពិសោធន៍គួរកំណត់បរិមាណទឹកឲ្យស្មើគ្នាគ្រប់ក្រុមដូចអំបិលដែរ ។<br>- គួរស រសេរចំណងជើងមេរៀនដាក់លើក្ដារខៀន<br>- គួរនិយាយឲ្យបានច្រើន<br>- គួរឲ្យសិស្សក្នុងក្រុមឡើងរាយការណ៍ទើបល្អ<br>- ណែនាំតាមក្រុមឲ្យច្បាស់<br>- ចែកសម្ភារៈពិសោធន៍គួរតែណែនាំឲ្យច្បាស់តាមក្រុមនីមួយៗ ។<br>- គួរឲ្យសិស្សតំណាងក្រុមណាមួយបានទៅពិនិត្យមើលក្រុមដទៃដែលបានពិសោធន៍រួច ។<br>- ចំនួននៃការពិសោធន៍ ហាក់ដូចជាច្រើនពេក<br>- វត្ថុរឹងដែលយកមកពិសោធន៍ធ្វើឲ្យសិស្សពិបាកយល់ដោយលទ្ធផលមានភាពមិនសូវច្បាស់ តាមគំនិតខ្ញុំ គួរតែប្រើប្រាស់ទឹកកកជំនួសអំបិល ។<br>- គួរអនុវត្តរយៈពលេបង្រៀនតាមពេលគ្រោងទុកក្នុងកិច្ចតែងការបង្រៀន ។<br>- ប្រើរយៈពេលវែង (៦០នាទី) គួរកែត្រឹមរយៈពេល (៤០នាទី) |

- ពេលសួរសំណួរគួរផ្លាស់ប្តូរតាមក្រុមកុំសួរតែ ១ក្រុម
- គួរតែឲ្យសិស្សជាអ្នករិះរកប្លង់ពិសោធន៍ដោយខ្លួនឯង
- ពេលសួរសំណួរ គួរផ្លាស់ប្តូរពីក្រុមមួយទៅក្រុមមួយ
- បរិយាកាសថ្នាក់ស្ងៀមស្ងាត់
- គួរប្រាប់សិស្សឲ្យប្រុងប្រយ័ត្នក្នុងការប្រើប្រាស់សម្ភារៈ (ទឹកក្តៅ កែវក្រឹត)
- គួរឲ្យសិស្សទស្សន៍ទាយតាមក្រុម ។
- គ្រូអត់មានធ្វើប្លង់ពិសោធន៍
- បង្រៀនគ្មានការលើកទឹកចិត្តសិស្ស

# កិច្ចតែងការបង្រៀន

មុខវិជ្ជា វិទ្យាសាស្រ្តអនុវត្ត
ថ្នាក់ទី៣
ជំពូកទី១
មេរៀនទី២ ៉ផលប្រយោជន៍រុក្ខជាតិ៉
១. រុក្ខជាតិផ្តល់ជាអាហារ(រយៈពេល ៤០នាទី)

I– វត្ថុបំណងៈ

ចំណេះដឹង ប្រាប់ពីផ្នែកផ្សេងៗ នៃរុក្ខជាតិអាហារ ដល់មនុស្សបានត្រឹមត្រូវ តាមរយៈការសង្កេតជាក់ស្តែង និងសំណួរបំផុសរបស់គ្រូ។

បំណិន កំណត់បានត្រឹមត្រូវ ពីផ្នែកផ្សេងៗនៃរុក្ខជាតិ ដែលផ្តល់ផលប្រយោជន៍ជាអាហារតាមរយៈការពិភាក្សាក្រុម។

ឥរិយាបថ ទម្លាក់សិស្សអោយចេះប្រើប្រាស់ និងជ្រើសរើសផលនៃរុក្ខជាតិក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

II– សម្ភារៈ

សៀវភៅវិទ្យាសាស្រ្តអនុវត្ត ថ្នាក់ទី៣ ទំព័រទី៦
រុក្ខជាតិ: បន្លែ ដើម ស្លឹក ផ្កា ផ្លែ មើម ត្រួយ និងសន្លឹកកិច្ចការ ប័ណ្ណពាក្យ

III–ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . តើមានអ្នកឈប់ប៉ុន្មាននាក់?<br>. វេនក្រុមណាបោស?<br>. សំលៀកបំពាក់ស្អាតបាត ស្មៀមស្ងាត់ | ជំហានទី១<br>លំនឹងថ្នាក់ (២នាទី)<br>. អវត្តមាន<br>. អនាម័យ<br>. សណ្តាប់ធ្នាប់ | តំណាងថ្នាក់រាយការណ៍ |
| . តើរុក្ខជាតិទាំងនោះផ្តល់ប្រយោជន៍អ្វីខ្លះដល់មនុស្សយើង? ចូររៀបរាប់។<br>. ថ្ងៃនេះយើងរៀន មេរៀនអ្វី? | ជំហានទី២<br>រំលឹកមេរៀន (៥នាទី)<br>. ថ្នាក់រុក្ខជាតិចែកជា៤ផ្នែក: រុក្ខជាតិធំ វល្លិ៍ ទាប ស្មៅ<br>. ជាអាហារ សំណង់ ឱសថ និងតំបាញ។ | . មាន៤ផ្នែក រុក្ខជាតិ វល្លិ៍ ទាប ស្មៅ<br>. អាហារ សំណង់ ឱសថ និងតំបាញ។ |

| | | |
|---|---|---|
| សរសេរចំណងជើងមេរៀន លើក្ដារខៀន។<br>. បង្ហាញពីផ្នែកផ្សេងៗនៃរុក្ខជាតិមួយចំនួន<br>. តើនេះជាអ្វី?<br>បិទសំណួរគន្លឹះលើក្ដារខៀន | ជំហានទី៣<br>មេរៀនថ្មី (២៦នាទី)<br>ផលប្រយោជន៍រុក្ខជាតិ<br>១) រុក្ខជាតិផ្ដល់ជាអាហារ<br>. ក្រូច ត្រឡាច ត្រសក់ ការុត ឆៃថាវ ត្រកួន ចេក.... | ត្រកួន ការុត ក្រូច ខ្នុរ ចេក អំពៅ ត្រឡាច ម្ទេស ស្លឹកគ្រៃ...។ |
| | តើផ្នែកណាខ្លះនៃរុក្ខជាតិដែលផ្ដល់ជាអាហារដល់មនុស្សយើង? | |
| . ចែកសន្លឹកកិច្ចការតាមក្រុម<br>សម្មតិកម្ម<br>តើរុក្ខជាតិទាំងនេះហូបបានរឺទេ?<br>. អោយពិភាក្សាតាមក្រុម រួចបំពេញសន្លឹកកិច្ចការ<br><br>. អោយតំណាងក្រុមឡើងរាយការណ៍<br>. គ្រូកែលម្អសេចក្ដីសន្និដ្ឋាន | រុក្ខជាតិខ្លះហូបបាន ខ្លះហូបមិនបាន និងខ្លះទៀត ហូបបានតែផ្នែកណាមួយប៉ុណ្ណោះ។<br><br>សន្និដ្ឋាន:<br>ដើម ស្លឹក មើម ផ្កា ផ្លែ រុក្ខជាតិមួយចំនួនធ្វើជាអាហាររបស់យើង។ | សិស្សចូលតាមក្រុម<br><br>បាន មិនបានបំពេញសន្លឹកកិច្ចការ<br><br>. តំណាងក្រុមឡើងរាយការណ៍ |
| . ចែកប័ណ្ណពាក្យតាមក្រុម រួចអោយឡើងបិទលើក្ដារខៀន<br><br>. អោយសិស្សស្ម័គ្រចិត្ត ២ នាក់ ឡើងមកលេងល្បែង | ជំហានទី៤<br>ពង្រឹងចំណេះដឹង<br>រុក្ខជាតិហូបបាន ហូបមិនបាន<br>ផ្លែក្រូច ផ្កាចន្ទ<br>ផ្លែត្រប់... ផ្លែស្លែង...<br>"ផល្លាសំដែងឫទ្ធិ" | ឡើងបិទប័ណ្ណពាក្យ<br><br>ស្ម័គ្រចិត្តលេង |

| | | |
|---|---|---|
| ប្អូនៗកត់មេរៀនសង្ខេបចូល ក្នុងសៀវភៅ<br>. ប្អូនៗត្រូវចេះជ្រើសរើស បន្លែ ផ្លែឈើណាដែលហូបបាន និងផ្តល់សុខភាពល្អដល់យើង។ | ជំហានទី៥<br>កិច្ចការផ្ទះបណ្តាំផ្ញើ (២នាទី)<br>មេរៀនសង្ខេប<br>រុក្ខជាតិផ្តល់ផលប្រយោជន៍ជាច្រើនដល់យើង។ ផ្នែកផ្សេងៗរបស់រុក្ខជាតិ ដូចជា: ដើម មើម ស្លឹក ផ្កា ផ្លែ មួយចំនួនធំធ្វើជាអាហារ របស់មនុស្ស។ | . សិស្សអនុវត្តតាម |

## សន្លឹកកិច្ចការ

១. តើផ្នែកណាខ្លះនៃរុក្ខជាតិដែលផ្តល់ជាអាហារដល់មនុស្សយើង?

បង្កើតសម្មតិកម្ម

-----------------------------------------------

-----------------------------------------------

-----------------------------------------------

២. ចូរបំពេញតារាងខាងក្រោម ដោយរកឈ្មោះ លក្ខណៈ និងផ្នែករបស់រុក្ខជាតិ។

| ឈ្មោះរុក្ខជាតិ | លក្ខណៈ:(ពណ៌ ក្លិន រស ទ្រង់ទ្រាយ ទន់ រឹង...) | ផ្នែកនៃរុក្ខជាតិ |
|---|---|---|
| ក្រូចពោធិ៍សាត់ | បៃតង ផ្អែម មូលរលោងទន់ មានសំបក | ផ្លែ |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

៣. តើគ្រប់ផ្នែកនៃរុក្ខជាតិ សុទ្ធតែបរិភោគបានឬទេ? ព្រោះអ្វី?

-----------------------------------------------

-----------------------------------------------

-----------------------------------------------

សន្និដ្ឋាន

-----------------------------------------------

-----------------------------------------------

-----------------------------------------------

# យោបល់ និងសំណូមពរ

ចំណុចល្អ
- សិស្សឆ្លើយសំនួររបស់គ្រូដែលទាក់ទងមេរៀនចាស់
- សិស្សធ្វើចំណែកថ្នាក់រុក្ខជាតិហូបផ្លែ
- សិស្សក្នុងក្រុម ទាញសេចក្តីសន្និដ្ឋាន
- ទំនាក់ទំនង Objective នឹងលទ្ធផលនៃអ្នកសិក្សា
- សំនួរគន្លឹះ
- ចែកសម្ភា:ជាក់ស្តែង
- ផ្តល់សន្លឹកកិច្ចការពិភាក្សា
- រាយការណ៍អំពីលទ្ធផលពិភាក្សាតាមប្រភេទរុក្ខជាតិ
- បានបំផុសខ្លឹមសារច្បាស់ស្របតាមគោលបំណងមេរៀន
- រៀបចំកិច្ចតែងការ ដែលមាន ៥ជំហាន និងសម្ភារ:គ្រប់គ្រាន់
- សកម្មភាពគ្រូ តិចជាងសកម្មភាពសិស្សដោយគ្រាន់តែបំផុសបញ្ហានិងដាក់សំនួរ
- បញ្ចូលល្បែងពង្រឹងចំណេះដឹង លើខ្លឹមសារមេរៀន ។
- សំលេងច្បាស់ក្នុងការបង្រៀន
- គ្រូបានពង្រីកចំណេះដឹងក្រោយពេលបញ្ចប់មេរៀន
- បង្រៀននិងរៀនតាមបែបវិធីសាស្ត្រិះរក
- បង្រៀនតាមលំនាំវិទ្យាសាស្ត្រ
- មានការប្រើប្រាស់ប័ណ្ណសំនួរនិងពាក្យ
- គ្រូធ្វើសំយោគលើសេចក្តីសន្និដ្ឋានរបស់សិស្ស។

ចំណុចកែលម្អ
- ការបង្រៀនរបស់អ្នកឲ្យបានល្អទាំងសកម្មភាពគ្រូ និងសកម្មភាពសិស្ស ហើយ ឆ្លើយតបទៅនឹងវត្ថុបំណងមេរៀន ។
- ការបង្រៀនលើសម៉ោងកំណត់ (ក្នុងឱកាសតែងការ រយ:ពេលបង្រៀនតើ ៤០នាទីទេ ប៉ុន្តែអ្នកគ្រូបង្រៀនរហូតដល់ ៦៥នាទី )
- ក្នុង Pre គ្មានលក្ខណ:រុក្ខជាតិ តែក្នុង Work Sheet មានវិញ
- ត្រូវបញ្ជាក់អំពីប្រភេទរឹស និង ធាង
- ពេលសិស្សបិទខុសត្រូវឡើងបិទឲ្យត្រូវចំពោះផ្លែស្លែងមិនត្រូវបញ្ជាក់ថាញុំបានទេ ?
- គ្មានបន្ថែមការងារដៃគូ នៅពេលដែលអ្នកគ្រូឲ្យសិស្សកិច្ចការសំនួរទី1 និងពន្យល់ ពាក្យ "សម្មតិកម្ម" និង

បន្ថែមក្នុងកិច្ចតែងការ ។
- គួរយកមេរៀនសង្ខេប បញ្ចូលទៅក្នុងជំហានទី៣ វិញ
- នៅក្នុងកិច្ចតែងការ គួរបង្ហាញពីចម្លើយប៉ាន់ស្មានរបស់សិស្សមុនបានចម្លើយពិត ពីសិស្ស ។
- គ្រូគួរលើកបង្ហាញរុក្ខជាតិម្ដងសួរសិស្ស ញុំាបាន ឬមិនបាន........
- ការសំយោគខ្លឹមសារមេរៀនរបស់គ្រូ គួរកំណត់ខ្លឹមសារឲ្យបានច្បាស់លាស់ ចៀសវាង ការប្រកែកចាញ់ឈ្នះរបស់សិស្ស ពិសេសឲ្យស្របទៅនឹងកម្រឹតសមត្ថភាពសិស្សថ្នាក់ទី ៣ ។
- ការប្រើប្រាស់សំនួរ ហាក់ដូចជាមានការត្រួតគ្នា
- មេរៀនសង្ខេបគួរធ្វើនៅជំហានទី ៤ ដើមឬធាងជំហានទី៣
- ខ្វះទំនាក់ទំនងមេរៀន
- ល្បែងខ្វះការប្រលងប្រណាំង ខ្វះភ្លក់រសជាតិ ជូរផ្អែម
- អ្នកគ្រូត្រូវបង្ហាញពីប្រភេទនៃរុក្ខជាតិស្គាល់សិន
- ត្រូវតែប្រយ័ត្នចំពោះរុក្ខជាតិពុលដែលហូបមិនបានមុននិងឲ្យសិស្សភ្លក់
- គួរឲ្យសិស្សបង្កើតសម្មតិកម្មសិនចាំចែកសម្ភារៈឲ្យសិស្សសង្កេត
- គួរសរសេរដាក់ផ្ទាំងធំ នូវរាងមើម ផ្លែ ដើម ផ្កា ស្លឹក ដើម្បីឲ្យសិស្ស បានក្រុម ស្រង់ចូល ។
- នៅពេលស្រង់ពត៌មានចំលើយសិស្សគួរបង្កើតតារាងលើក្រដាសផ្ទាំងធំ (តារាង ឈ្មោះ-លក្ខណៈ-ផ្នែកនៃរុក្ខជាតិ ឬហូបបាន និងមិនបាន) ។
- ត្រង់សំនួរគន្លឹះគួរៈ
- បង្ហាញសម្មតិកម្មរួច សួររករុក្ខជាតិដែលហូបបានឬស មើម ផ្លែ ស្លឹក
- ផ្ដល់សម្ភារៈហើយឲ្យក្រុមជ្រើសរើស និងញែក
- ឲ្យសិស្សសម្របសម្រួលផ្សេងៗ
- ប្រើសំនួរគន្លឹះ គួរតែសិស្សទស្សទាយ
- ចែកសម្ភារៈតាមក្រុមពិនិត្យលើការទស្សទាយរបស់សិស្ស
- សម្ភារៈឲ្យសិស្សសង្កេតតាមក្រុមគួរតែឲ្យ រាយការណ៍ និងលើកបង្ហាញម្តងមួយៗប្រាប់ទៅក្រុមដទៃ ។
- គ្រូគួរប្រើតារាងលើក្តារខៀនឲ្យសិស្សឡើងបំពេញ ។
- ក្នុងវត្ថុបំណងកន្លែងឥរិយាបថកុំប្រើពាក្យចេះ
- ក្នុងជំហានទី ៣ សុំបញ្ជាក់ពីក្នុងការផ្ដល់សម្ភារៈ
- ក្នុងការចែកសន្លឹកកិច្ចការតាមក្រុមតែបំពេញជាបុគ្គល ដូចនេះកិច្ចតែងការ សូមដាក់ចែកសន្លឹកកិច្ចការតាមក្រុម តែបំពេញជាបុគ្គល ។
- អ្នកគ្រូឲ្យសិស្សបំពេញនៅក្នុងសន្លឹកកិច្ចការ ពេលដែលសិស្សបាននៅចំនុចទី២ ខាងលើ ។
- ពេលពិភាក្សាក្រុម គួរឲ្យសិស្សភ្លក់ ឬហូបសាកមើលដើម្បីឲ្យដឹងថា រុក្ខជាតិណា ផ្អែម សាប ល្វីង ជូរចត់
- គ្មានការលើកទឹកចិត្តសិស្សគ្រប់ពេល។

# ៣.

# ផែនការអនុវត្ត

# ការសិក្សាស្រាវជ្រាវមេរៀន

# នៅក្នុង

# សាលាគរុកោសល្យ នឹងវិក្រឹតការខេត្ត

*ក្រុមសិក្សាស្រាវជ្រាវមេរៀន* (*ក្រដាស* A4)

# សាលាគរុកោសល្យនិងវិក្រឹតការរាជធានី ភ្នំពេញ

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោក រ៉ូវ ផេងសែ | នាយកសាលា ប្រធាន |
| ២ | អ្នកស្រី សក់ សារ៉ន | នាយករង អនុប្រធាន |
| ៣ | លោក ណាយ ឆោមយ៉ា | នាយករង អនុប្រធាន |
| ៤ | លោក ជួង ចន្ថា | គ្រូឧទ្ទេសវិទ្យាសាស្ត្រ សមាជិក |
| ៥ | លោក សែម សារុធ | គ្រូឧទ្ទេសវិទ្យាសាស្ត្រ សមាជិក |
| ៦ | លោក ថោង កុសលឫទ្ធិ | ប្រធានផ្នែកសិក្សា(គណិតវិទ្យា) សមាជិក |
| ៧ | កញ្ញា ទិត និមល | អនុប្រធានផ្នែកសិក្សា(ចិត្តគរុ.) សមាជិក |
| ៨ | លោក ឌុក ភានី | ប្រធានផ្នែករដ្ឋបាល(ភាសារខ្មែរ) សមាជិក |
| ៩ | លោក ជា រតនា | អនុប្រធានផ្នែករដ្ឋបាល(គណិតវិទ្យា) សមាជិក |
| ១០ | លោក មុន ឡូត | ប្រធានក្រុមបច្ចេកទេស(ភាសារខ្មែរ) សមាជិក |
| ១១ | លោក ពេជ កុសល | ប្រធានក្រុមបច្ចេកទេស(ភាសារខ្មែរ) សមាជិក |
| ១២ | លោក គង់ ចន្ទី | ប្រធានក្រុមបច្ចេកទេស(សិក្សាសង្គម) សមាជិក |
| ១៣ | លោក ម៉ា រិទ្ធី | ប្រធានក្រុមបច្ចេកទេស(គណិតវិទ្យា) សមាជិក |
| ១៤ | លោក វិញ ដារ័ត្ន | គ្រូឧទ្ទេសគណិតវិទ្យា សមាជិក |
| ១៥ | លោក កែវ ទូច | គ្រូឧទ្ទេស ICT សមាជិក |
| ១៦ | អ្នកស្រី គាំ សុខអណ្តែត | គ្រូឧទ្ទេសភាសាខ្មែរនិងវិទ្យាសាស្ត្រអប់រំ |

ហត្ថលេខា

______________________

នាយក TTC

* អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

# កាលវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន

## សាលាគរុកោសល្យនិងវិក្រឹតការរាជធានី ភ្នំពេញ

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | បង្រៀនសាកល្បងសម្រាប់ ពង្រាងកិច្ចតែងការលើកទី២ + កែលម្អ | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | កែលម្អកិច្ចតែងការបង្រៀនលើក ទី១ដោយក្រុម LS | | អនុវត្តបង្រៀនក្នុងថ្នាក់និងសង្កេត កែលម្អមេរៀន | | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | វិទ្យាសាស្ត្រអនុវត្ត<br><br>សែម សារុធ | | | | | |

| សប្តាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | កែលម្អកិច្ចតែងការបង្រៀនលើកទី១មេរៀនទី២ ដោយក្រុម LS | អនុវត្តក្នុងថ្នាក់និងសង្កេតកែលម្អមេរៀន | | |
| ២ | | បង្រៀនសាកល្បងសម្រាប់ពង្រាងកិច្ចតែងការបង្រៀនលើកទី២ + កែលម្អ | | | |
| ៣ | | | | | |
| ៤ | | | | | |
| មុខវិជ្ជា<br>ប្រធានបទ<br>អ្នកទទួលប្រធានបទ | | វិទ្យាសាស្ត្រអនុវត្ត<br><br>សែម សារុធ | | | |

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | | | អនុវត្តក្នុងថ្នាក់–សង្កេត និងកែលម្អ | កែលម្អពង្រាងកិច្ចតែងការបង្រៀន លើកទី១ ដោយក្រុម LS | អនុវត្តក្នុងថ្នាក់–សង្កេត និងកែលម្អ |
| ២ | | | កែលម្អពង្រាងកិច្ចតែងការបង្រៀន លើកទី១ ដោយក្រុម LS | | | |
| ៣ | | | | | បង្រៀនសាកល្បងនិងពិភាក្សា ពង្រាងកិច្ចតែងការបង្រៀនលើក ទី២ | |
| ៤ | | | បង្រៀនសាកល្បងពង្រាងកិច្ចតែង ការបង្រៀនលើកទី១<br>កែលម្អ | | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | | | វិទ្យាសាស្ត្រអនុវត្ត<br><br>ជួង ចន្ថា | | វិទ្យាសាស្ត្រអនុវត្ត<br><br>ជួង ចន្ថា | |

| សប្ដាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | | | | |
| ២ | | | | អនុវត្តក្នុងថ្នាក់–សង្កេត និងកែលម្អ | |
| ៣ | | | កែលម្អពង្រាងកិច្ចតែងការបង្រៀនលើកទី១ ដោយក្រុម LS | | |
| ៤ | | | បង្រៀនសាកល្បងនិងពិភាក្សាកែលម្អកិច្ចតែងការបង្រៀនលើកទី២ | | |
| មុខវិជ្ជា<br>ប្រធានបទ<br>អ្នកទទួលប្រធានបទ | | | វិទ្យាសាស្ត្រអនុវត្ត<br><br>លោក ដួង ចន្ថា | | |

*ក្រុមសិក្សាស្រាវជ្រាវមេរៀន (ក្រដាស A4)*

# សាលាគរុកោសល្យនិងវិក្រឹតការខេត្ត កណ្ដាល

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោកស្រី ឈិន សុវណ្ណ | ប្រធាន |
| ២ | លោក ស៊ុក ប៊ុនសុង | អនុប្រធាន |
| ៣ | លោកស្រី ឈន ចន្ទលីផល | អនុប្រធាន |
| ៤ | លោក ស៊ុក សុគន្ធ | អនុប្រធាន |
| ៥ | លោក នៅ អាន | អនុប្រធាន |
| ៦ | លោកស្រី ស្រ៊ាង សុភា | សមាជិក ជីវវិទ្យា |
| ៧ | លោក ជួន សុជាតិ | សមាជិក ជីវវិទ្យា |
| ៨ | លោកស្រី សួស សេងហួត | សមាជិក រូបវិទ្យា |
| ៩ | លោកស្រី លឿង សុជាណារ៉េត | សមាជិក គីមីវិទ្យា |
| ១០ | ប្រធានក្រុមបច្ចេកទេសក្រុមមុខវិជ្ជា | សមាជិក |
| ១១ | | |
| ១២ | | |
| ១៣ | | |

ហត្ថលេខា

________________

នាយក TTC

* អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

# កាលវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន

## សាលាគរុកោសល្យនិងវិក្រឹតការខេត្ត      កណ្ដាល

| សប្ដាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | បង្រៀនដល់គរុសិស្សឆ្នាំទី១ កែលម្អដោយក្រុម LS | ប្រជុំ LS កែលម្អកិច្ចតែងការ | ប្រជុំ LS កែលម្អកិច្ចតែងការ | | ប្រជុំ LS កែលម្អកិច្ចតែងការ |
| ២ | | | | | ប្រជុំ LS កែលម្អកិច្ចតែងការ | |
| ៣ | ប្រជុំ LS កែលម្អកិច្ចតែងការ | | បង្រៀនសាកល្បងដល់គ្រូឧទ្ទេស កែលម្អ | បង្រៀនសាកល្បងដល់គ្រូឧទ្ទេស កែលម្អ | បង្រៀនសាកល្បងដល់គ្រូឧទ្ទេស កែលម្អ | បង្រៀនសាកល្បងដល់គ្រូឧទ្ទេស កែលម្អ |
| ៤ | បង្រៀនសាកល្បងដល់គ្រូឧទ្ទេស កែលម្អ | | បង្រៀនដល់គរុសិស្សឆ្នាំទី២ កែលម្អដោយក្រុម LS + គ្រូឧទ្ទេស | បង្រៀនដល់គរុសិស្សឆ្នាំទី២ កែលម្អដោយក្រុម LS + គ្រូឧទ្ទេស | បង្រៀនដល់គរុសិស្សឆ្នាំទី១ កែលម្អដោយក្រុម LS + គ្រូឧទ្ទេស | បង្រៀនដល់គរុសិស្សឆ្នាំទី១ កែលម្អដោយក្រុម LS + គ្រូឧទ្ទេស |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | ប្រធានបទ "ភ្នែក"<br>លឿង សុផាណារ៉េត | | ការបន្តពូជសត្វ<br>ជួន សុជាតិ | កំណកញើស<br>ស្រ៊ាង សុភា | លក្ខណៈរបស់រុក្ខជាតិ<br>ជួន សុជាតិ | អាមីដុង<br>សួស សេងហួត |

| សប្ដាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | | | | ប្រជុំ LS កែលម្អកិច្ចតែងការ |
| ២ | | | | | |
| ៣ | | | | | បង្រៀនសាកល្បងដល់គ្រូឧទ្ទេស កែលម្អ |
| ៤ | | | | | បង្រៀនដល់គរុសិស្សឆ្នាំទី១<br>កែលម្អដោយក្រុម LS + គ្រូឧទ្ទេស |
| មុខវិជ្ជា<br>ប្រធានបទ<br>អ្នកទទួលប្រធានបទ | | | | | ឃ្នាស់<br>លឿង សុផាណារ៉េត |

*ក្រុមសិក្សាស្រាវជ្រាវមេរៀន (ក្រដាស A4)*

# សាលាគរុកោសល្យនិងវិក្រឹតការខេត្ត បន្ទាយមានជ័យ

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
